# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0175**

## សម្ភាសន៍ជាមួយឈ្មោះ ធន់ ដារ៉េត ហៅ ធន់ ថេង ភេទស្រី អាយុ៤៤ឆ្នាំ និងម្ដាយ មុខងារនៅសម័យខ្មែរក្រហមៈ «កងកុមារ»

## សព្វថ្ងៃរស់នៅភូមិប៉ោយព្រីង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន និង ចាន់ ប្រុញ

០១:២៧:៥៧

៤៦ទំព័រ

ប៊ុនថន ៖ រៀបរាប់អ៊ីដែលមីងចាំមីង?

អ្នកជិតខាង ៖ រៀបរាប់សម័យ ប៉ុល ពត នោះ!

ប៊ុនថន ៖ បាទ! ពីតូចមក អ៊ីចឹងខ្ញុំសូមសួរឈ្មោះមីងតែម្ដង?

ដារ៉េត ៖ ខ្ញុំឈ្មោះក្នុងបញ្ជីឈ្មោះ ធន់ ដារ៉េត ឈ្មោះក្រៅឈ្មោះ ធន់ ថេង ហៅក្រៅ ។

ប៊ុនថន ៖ គុណ ដារ៉េត?

ដារ៉េត ៖ ចាំ! ធន់ ដារ៉េត ។

ប៊ុនថន ៖ ហៅ គុណ?

ដារ៉េត ៖ ហៅក្រៅហៅ ធន់ ថេង ហៅឈ្មោះ ថេង ។

ប៊ុនថន ៖ ធន់ ថេង?

ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ បាទ! អ្នកមីងអាយុប៉ុន្មានហើយ?

ដារ៉េត ៖ ខ្ញុំអាយុ៤៤ហើយ ។

ប៊ុនថន ៖ ៤៤ឆ្នាំ?

ដារ៉េត ៖ បាទ!

ប៊ុនថន ៖ មីងស្រុកកំណើតនៅភូមិឃុំអីដែរអ្នកមីង?

ដារ៉េត ៖ ខ្ញុំនៅប៉ោយព្រីងនេះឯង ។

ប៊ុនថន ៖ ប៉ោយព្រីង?

ដារ៉េត ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ប៊ុនថន : បាទ! មីងបងប្អូនប៉ុន្មាននាក់មីង?

ដារ៉េត : ខ្ញុំកាលដែលម៉ែខ្ញុំពីដើមមកមានតែបីនាក់ទេ ។ ដល់ពេលអាពតរួចមកគាត់ឆាប់យកគ្រួសារគាត់ទៅវាយចោល ក៏បានមួយទៀត បានពីនាក់ទៀត ។

ប៊ុនថន : បាទ! ចឹងប្រាំនាក់ទាំងមុនទាំងក្រោយ?

ដារ៉េត : ចា៎!

ប៊ុនថន : ហើឪពុកម្ដាយអ្នកមីងនៅរស់ទេ?

ដារ៉េត : ម្ដាយខ្ញុំនៅ នោះគាត់នៅនោះ ។

ប៊ុនថន : អូ! នៅម៉ាំុដែរ?

ដារ៉េត : មិនមែននេះទេ នោះមួយទៀតធាត់ ។

ប៊ុនថន : អាយុប៉ុន្មានហើយ?

ដារ៉េត : ម៉ែខ្ញុំ៦០ជាងហើយ ។

ប៊ុនថន : ចោះឪពុក?

ដារ៉េត : ឪពុកខ្ញុំគាត់កើតឆ្នាំកុរ បងម៉ែខ្ញុំ១០ឆ្នាំជាង ។

ប៊ុនថន : ៧០ជាង?

ដារ៉េត : ៧០ជាងហើយដែលគេយកទៅវាយចោលនោះ ។ ចំណាស់ដែរ ។

អ្នកជិតខាង : កាលនៅសម័យអាពតឆ្នាំ៧០ប៉ុន្មាន!

ដារ៉េត : អត់ទេអាយុគាត់ប្រហែល៤០ជាងនោះឯង ។

ប៊ុនថន : អ្នកមីងបានរៀនសូត្រដល់ថ្នាក់ត្រឹមណាដែរមីង?

ដារ៉េត : រៀនថ្នាក់ទី៤បែកសម័យវៀតណាមហើយ ។

ប៊ុនថន : ទី៤ក្រោយហើយ?

ដារ៉េត : ចា៎! សម័យវៀតណាម ។

ប៊ុនថន : ចោះមុនមីងអត់បានរៀនទេពីមុនសម័យ ប៉ុល ពត?

ដារ៉េត : សម័យអា ពត ក៏អត់បានរៀន ។ គេឲ្យជញ្ជូនដី ជញ្ជូនអាចម៍គោ គេឲ្យដេកឆ្ងាយពីម៉ែ ។ ថាស្អីទៅជាន់ប៉ុណ្ណេះៗ ខ្មៅស្គុលៗក្រុមកុមារ ផ្ទះកុមារគេឲ្យដេក ។ ម៉េចសម័យនោះសម្បូរស្អីជាន់ដែរលោកគ្រូ!

ប៊ុនថន : ជាន់ម៉េចវិញមីង?

ដារ៉េត : ដឹងថារូបអីដូចប្រែត ដូចចារាំង មកស្ដឹងគេជាន់យើងត្រង់ស្លូកកំរើកចេះក៏មិនរួចៗ ។

ប៊ុនថន :	អូ! ជាន់គេហៅខ្មោចសន្កត់?

ដារ៉េត :	នោះឯង អញ្ចុះឯង ។ ដូចមានអីជាន់ មានអីសន្កត់ ។

ប៊ុនថន :	បាទ?

ដារ៉េត :	ចោះគេឲ្យដេកឆ្ងាយពីម៉ែពីឪ ក្រុមកុមារ ។

អ្នកជិតខាង :	កុមារា កុមារីមិនដែលដេកជាមួយគ្នាទេ ។

ប៊ុនថន :	មីងនៅកងកុមារកាលហ្នុង?

ដារ៉េត :	ខ្ញុំថានៅកងកុមារក៏ដូចមិនមែននៅ នៅជាមួយម៉ែឪកាលហ្នុងនៅតូច គេហៅទៅប្រើម្តងៗ ។ ដល់ពេលយើងដេកជាមួយម្តាយ ប្រធានគេដើរប្រមូលមិនឲ្យដេកទេ គេឲ្យទៅដេកជាមួយកងកុមារក៏ទៅនឹងគេទៅ ក៏រត់មករកម្តាយវិញទៅ ។ ឆ្វារចុះឆ្វារឡើងដដែលហ្នឹងណ៎ា!

ប៊ុនថន :	អាយុប៉ុន្មានឆ្នាំមីង?

ដារ៉េត :	កាលនោះប្រាំឆ្នាំទេ ក៏ប្រាំបីឆ្នាំដឹង ។

ប៊ុនថន :	ប្រាំបីប្រាំបួនឆ្នាំ ។ ចោះមីងឪពុកម្តាយមីងនៅភូមិហ្នឹងក៏គាត់នៅណា?

ដារ៉េត :	ឪពុកខ្ញុំនៅភូមិប៉ោយតាប៉ែន ម្តាយខ្ញុំនៅប៉ោយព្រីងនេះឯង ។ ដល់ពេលគាត់បានគ្នាទៅគាត់ធ្វើទ័ពធ្វើទាហានណា ។ ដល់ធ្វើទាហានទៅ ចេះតែនៅតាមស្វាយរៀងចេះតែចល័ត ។ ប្រពន្ធទាហានចេះតែចល័តទៅ ទាល់តែនៅថ្មពួក ។ គេជម្លៀសពីថ្មពួកនោះមកលោកគ្រូ ។ ជម្លៀសថ្មពួកមកណេះវិញ ប្រុងរត់ទៅប្រទេសថៃ គេថាអ្នករត់ទៅងាប់អស់ពីរបីឡានហើយក៏មិនបានរត់ទៅ ។ អាថ្ងៃនោះមក បានគេវាយចោលនោះណ៎ា!

ប៊ុនថន :	ចឹងគាត់ធ្វើទ័ព?

ដារ៉េត :	ចា៎! ទាហាន ។

ប៊ុនថន :	ទ័ពខាង លន់ នល់?

ដារ៉េត :	ចា៎!

ប៊ុនថន :	ចឹងគាត់ជម្លៀសទៅខេត្តណាខ្លះ ។ អូ! ទៅមិនមែនជម្លៀសទេគាត់បេសកម្មទៅធ្វើ?

ដារ៉េត :	ចា៎!

ប៊ុនថន :	នៅណាខ្លះមីង?

ដារ៉េត ៖ គ្រប់តែខេត្ត គ្រាន់តែថាខាងពួងខាងអី ម៉ែខ្ញុំបានគាត់ច្បាស់ៗ ទៅខាងបានក្បែរអីនៅពួងហ្នឹងហើយគាត់ទៅ ទៅគ្រប់ទិសនោះឯងៗ ហឺអ្នកលឿងៗ

ប៊ុនថន ៖ អ្នកលឿងព្រៃវែង?

ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ ទៅព្រៃវែង ទៅណាទៀតអ្នកមីង?

ដារ៉េត ៖ ខ្ញុំមិនដឹងច្បាស់ទេ ព្រោះអីខ្ញុំនៅតូចណាស់ៗ បើម៉ែខ្ញុំបានច្បាស់ៗ ស្រីរ័ត្ន ឲ្យម៉ែមកនេះភ្លេត

ប៊ុនថន ៖ ចាំសួរមីងហើយចាំសួរអ៊ីស្រីៗ អ្នកមីងគាត់ទៅម្ដងៗយូរទេទៅធ្វើការអីចឹងនៅតាមខេត្ត?

ដារ៉េត ៖ ទៅម្ដងៗយូរដែរៗ កាលនោះខ្ញុំនៅស្រពេចស្រពិលណាស់លោកគ្រូៗ

ប៊ុនថន ៖ បាទ?

ដារ៉េត ៖ នៅស្រពេចស្រពិលមិនទាន់ច្បាស់ទេៗ

ប៊ុនថន ៖ គាត់ទៅច្បាំងឬក៏ម៉េច?

ដារ៉េត ៖ ចា៎! ទៅច្បាំង គេជម្លៀសទៅៗ

ប៊ុនថន ៖ ខាង លន់ នល់ ទ័ព?

ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ កាលនោះគាត់ស័ក្កិអីប៉ុន្មានដែរដូចថាឋានៈគាត់?

ដារ៉េត ៖ ខ្ញុំអត់ដឹងថាគាត់ស័ក្តិអីទេ បើម៉ែខ្ញុំបានដឹងៗ

អ្នកជិតខាង ៖ គាត់អត់មានស័ក្តិទេកាលជំនាន់ ប៉ុល ពតៗ

ដារ៉េត ៖ គាត់អត់មានស័ក្តិទេ ប៉ុនស័ក្តិគាត់អត់មានធំប៉ុន្មានទេៗ

ប៊ុនថន ៖ ចោះ៧៥ហ្នឹងគាត់?

ដារ៉េត ៖ ៧៥ជម្លៀសមកនៅប៉ោយតាប៉ែនលោកគ្រូៗ

ប៊ុនថន ៖ បាទ! គាត់ជម្លៀសមកពីថ្មពួក?

ដារ៉េត ៖ ចា៎! ថ្មពួកមកប៉ោយតាប៉ែនៗ មកជម្លៀសនោះមកជាមួយម៉ែលោក ហុង ហ្នឹងឯងប៉ុនគាត់ស្គាល់ខ្ញុំទេៗ គាត់យកឪពុកខ្មែរក្រហមវាយទៅ ក៏គាត់ជម្លៀសមកជាមួយពួកខ្ញុំៗ

ប៊ុនថន ៖ កាលនោះគាត់កូនប៉ុន្មាននាក់ហើយ?

ដារ៉េត ៖ ម៉ែខ្ញុំនោះ!

ប៊ុនថន ៖ បាទ! ម្ដាយអ្នកមីង?

ដារ៉េត ៖ ម៉ែខ្ញុំ មើលខ្ញុំ ប្អូនខ្ញុំអា យឿន អាដែលឆាប់សម័យ ប៉ុល ពត ទម្ងន់មី ឆា បីនាក់ កូនបីនាក់ ។

ប៊ុនថន ៖ បីនាក់?

ដារ៉េត ៖ កូនក្នុងពោះមួយ ។ ចាំ!

ប៊ុនថន ៖ បីនាក់ទាំងក្នុងពោះមីង?

ដារ៉េត ៖ ទេប្អូននាក់ ។

ប៊ុនថន ៖ ប្អូននាក់នៅក្នុងពោះ?

ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ អ៊ីចឹងជម្លៀសមកហ្នឹងនៅនេះទាំងអស់?

ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ ដំបូងគាត់នៅណាមីង?

ដារ៉េត ៖ មកនៅតាប៉ែន១ទៅ ខ្មែរក្រហមចូលមកវាឲ្យជម្លៀស វែកស្ពឺ១កាត់ផ្លូវវាលនេះឯង ទៅនៅស្រែ ។ ទៅនៅស្រែ អានោះគេប្រជុំវាយចោល ។ នោះគេវាយ អាករ សម្លាប់ចោលនៅផ្លូវ ដឹងអាណាកូនអាណាណេះ ។ អាកសម្លាប់នៅផ្លូវនោះឈ្មោះប៊ុ រី ឈ្មោះអីនោះគេអាកសម្លាប់ស្រស់ៗ ។

ប៊ុនថន ៖ ប៊ុ រីនោះគាត់ធ្វើអីវិញ?

ដារ៉េត ៖ ធ្វើទាហាន មេទាហាន ។

ប៊ុនថន ៖ អ៊ីចឹងឲ្យតែទាហានគឺគេសម្លាប់តែម្ដង?

ដារ៉េត ៖ សម្លាប់ចោលទាំងអស់ ។ ចាំ!

ប៊ុនថន ៖ រី គាត់នៅភូមិណាដែរមីង?

ដារ៉េត ៖ នៅប៉ោយសំរោង ។

ប៊ុនថន ៖ ប៉ោយសំរោង?

ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ សម្លាប់តែគាត់ម្នាក់ គ្រួសារគាត់គេសម្លាប់ទេ?

ដារ៉េត ៖ ទាំអស់ ម៉ាគ្រួសារគាត់ទាំងអស់ ។

ប៊ុនថន : ប៉ុន្មាននាក់?

ដារ៉េត : កាលនោះប៉ុន្មានបងសាវៀន ប្រពន្ធគាត់ កូនគាត់ ម៉ែគាត់ផងនោះអី ប្អូនថ្លៃគាត់កាលហ្នឹង ។

ប៊ុនថន : ជួបអីវិញ! មីងនិយាយទៀតទៅមីង?

ដារ៉េត : ដល់ពេលចេញពីនោះមក គេឲ្យនៅប៉ុស្តិ៍ចាស់ ចេញពីប៉ុស្តិ៍ចាស់នៅប៉ោយសំរោង ។ អានៅប៉ោយសំរោងទៅ ឆ្នាំ៧០ប៉ុន្មានដែលគេចាប់នោះអ្ហេះ ។ ម៉ែឆ្នាំ៧០ប៉ុន្មានដែលគេចាប់ពុកទៅ?

ម្តាយ ដារ៉េត : ៧០ប៉ុន្មានទេ ៧៧ ។

ដារ៉េត : ខ្ញុំខំប្រាប់គាត់ថា៧៨ ។

ប៊ុនថន : បាទ! អត់អីទេមីង ។ ចោះគាត់ធ្វើការអីដែរអ៊ី?

ម្តាយ ដារ៉េត : គាគាត់ធ្វើការអី គាត់ធ្វើតែទាហាន ។

ប៊ុនថន : ឋានៈអីដែរ?

ម្តាយ ដារ៉េត : មិនមានឋានៈទេ ទាហានយើងគាត់ធម្មតា ។ គាត់មិនសូវចេះនិយាយចេះស្តី ទៅក៏មានបុណ្យមានស័ក្តិអីទេ ហើយគាត់ក៏អត់មានខ្សែរយៈទាក់ទងគេបានឡើងបានអី ។ណ៎ា!

ប៊ុនថន : ប៉ុនគាត់ខាង លន់ នល់?

ម្តាយ ដារ៉េត : អ្ហឺ! ខាង លន់ នល់ ។

ប៊ុនថន : ចោះគាត់ទៅណាខ្លះអ៊ីដូចថាគាត់គេបញ្ជូនគាត់ទៅវាយជាមួយខ្មែរក្រហមនៅខេត្តណាខ្លះទៅអ្នកលឿង?

ម្តាយ ដារ៉េត : ចា៎! នៅភ្នំស្រុកៗ ឈរជើងនៅស្វាយចេក នៅថ្មពួក ដល់ឈរជើងនៅថ្មពួករួចទៅគេឲ្យមកនៅស្វាយទំព័របានប្រហែលចំនួនកន្លះឆ្នាំបានឲ្យមកនៅស្វាយ ។ មកនៅស្វាយបានពីរយប់ គេឲ្យទៅនៅអ្នកលឿង ។ ទៅនៅអ្នកលឿងបាន៨ខែ រដ្ឋប្រហារទៅខ្ញុំសុំគេបានមកស្រុកវិញ ។ មកនៅថ្មពួកវិញចា៎!

ប៊ុនថន : អ្ហូ!

ម្តាយ ដារ៉េត : មកនៅថ្មពួកវិញប្រាំឆ្នាំអា ពត ចូលបណ្តោយ ។

ប៊ុនថន : បាទ! ចឹងគាត់កាលមកថ្មពួកហ្នឹងគាត់ខាងទាហានដដែលអ៊ី?

ម្តាយ ដារ៉េត : ចា៎! ទាហាន ។

ប៊ុនថន ៖ ខាង លន់ នល់?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ ចឹងអ៊ីគាត់ទៅហ្នឹងទៅតាមគាត់រហូតអ៊ី?

ម្ដាយ ដារ៉េត ៖ ចា៎! ទៅតាមរហូត។

ប៊ុនថន ៖ ទៅតាមហី?

ម្ដាយ ដារ៉េត ៖ ទៅដល់អ្នកល្បើងនោះដែលខ្ញុំបាននៅរស់រានមានជីវិត បានដូចថាទេវតាលោកប្រោសផងក៏មិនដឹង។ ខ្ញុំមិនដែលស្គាល់ភ្នំពេញបែមុខទៅខាងណាទេ កាលនោះទៅមានអ្នកល្បើងមានបងប្អូននៅជិតណាគេទៅសុំឈ្មោះបានផ្លាស់មកវិញ។ ហើយខ្ញុំក៏ទៅសុំអង្ករគេឲ្យតែគេណែជូនខ្ញុំទៅផងចោះ ព្រោះអីស្រណោះកូនខ្ញុំនៅឯផ្ទះច្រើនណាស់។ អង្ករគេទៅគេនាំទៅ ដែលគេនាំទៅលោកឈ្មោះលោក គឹមអាន ណារ៉េត ស័ក្តិ៧អីផ្កាយ៧ អ្ហីផ្កាយប៉ុន្មានទេខ្ញុំភ្លេចអស់ហើយ។

ប៊ុនថន ៖ ឈ្មោះអីអ៊ឹ គឹម?

ម្ដាយ ដារ៉េត ៖ គឹមអាន ណារ៉េត។

ប៊ុនថន ៖ គឹមអាន ណារ៉េត គាត់ទ័ពដែរ?

ម្ដាយ ដារ៉េត ៖ អត់ទេ។ គាត់អ្នកធ្វើការនៅក្នុងភ្នំពេញហ្នឹងឯង សម្រាប់ផ្លាស់ប្ដូរទាហាន។ ស្រាប់តែបានដល់ លោកនោះថាអ្ហីមិនអីទេមីអូនអើយ ព្រោះកូនខ្ញុំនៅក្នុងដៃយំតែង៉ាៗ។ នេះមីនេះ បាន៧ខែទម្ងន់ពីរខែ ព្រោះដាច់ដោះ ដល់ដាច់ដោះក៏យំអើយយំ។ ហីកូនគាត់ គាត់ថា១២នាក់ទាំងប្រុសទាំងស្រីប៉ុនៗលោកគ្រូឯងហ្នឹង។ ចា៎! ក៏ពរមីនេះដើរលេងនៅមាត់ទន្លេ ទៅអង្គុយនៅនឹងអាបង់នៅតាមមាត់ទន្លេ។ ពរចុះពរឡើងមិនចង់ឲ្យខ្ញុំមកទេ គាត់ចង់ស្ដាប់ខ្ញុំនិយាយ។

ប៊ុនថន ៖ បាទ! អ្នកបន្ទាយមានជ័យ?

ម្ដាយ ដារ៉េត ៖ អត់ទេនៅភ្នំពេញ។ ចា៎!

ប៊ុនថន ៖ បាទ! និយាយថាគាត់ចង់ស្ដាប់អ្នកបន្ទាយមានជ័យនិយាយតាដឹនៗអ៊ីចឹង?

ម្ដាយ ដារ៉េត ៖ គេថាខ្ញុំអត់មែនអ្នកបាត់ដំបងទេ គេថាខ្ញុំសៀមរាប។ ទៅខ្ញុំបាត់ដំបងទេ ថាខ្ញុំនៅខេត្តបាត់ដំបងទេ។ ហីក្មេងៗថាដូចជាមិនមែនទេ បើសៀមរាបជឿខ្លះ។ ហីពរមីកូនខ្ញុំមីនេះហើយ ទើបនឹងបានប្រាំពីរខែណោះឯង។ ចេះតែពរចុះពរឡើងទៅ។ មិនចង់ឲ្យខ្ញុំមក ម៉ោងប្រាំហើយនោះមិនចង់ឲ្យខ្ញុំមកទេ ចង់ស្ដាប់ខ្ញុំនិយាយតាំងលោកតា

លោកយាយ ។ បានថាលោកតាលោកយាយចោះ ព្រោះគាត់ចាស់ហើយ ហើកូនគាត់នៅក្មេងៗដប់ពីរនាក់ ។ ចេះតែពរម្នាក់ម្ដងៗទៅមិនចង់ឲ្យខ្ញុំមក ដល់ខ្ញុំមកបាន ។ ដល់គាត់ថាទៅសិនចោះកូនអើ្ហយ ចាំចំនួនកន្ទះទៀតបានឈ្មោះកូនឯងធ្លាក់ទៅ ថាចេះ ។ ខ្ញុំក៏មកទៅ ដល់ជម្រាបលាគាត់មកក៏ ខ្ញុំថាលោកឪអើយអាណិតកូនណែ ព្រោះអីកូនកំសត់វេទនាណាស់កូនតូចៗនៅជាមួយម្ដាយខ្ញុំចាស់ជរានៅភូមិស្រុក មិនដឹងយ៉ាងណាទេ ហើយកូននៅតូចៗផងនៅជាមួយគាត់ ។ ហើគាត់ក៏អាណិតអាសូរខ្ញុំទៅ ហើយគាត់ក៏ ។ ខ្ញុំលាគាត់មក គាត់ថាមិនអីទេកូនអើយប៉ាជួយ ។ ខ្ញុំហៅគាត់ថាលោកប៉ាៗ ចាំប៉ាជួយ ស្រាប់តែគាត់ថាចាំតែកន្ទះតែទៀតឈ្មោះនឹងធ្លាក់មកហើយ ថាមិនបាច់មកទៀតទេ អាណិតក្មេងតាមតែគាត់ ។ បានតែបីថ្ងៃ គាត់ណែដូចអាអកមីស្យុង រអោស្យុងដឹង ។

ប៊ុនថន : លិខិតខុទ្ទេសនាមអីគេហ្នឹង?

ម្ដាយ ដារ៉េត : ចា៎! អកមីស្យុងមិនដឹង សម្រាប់ជិះឡានមកនោះ ។ ពីដើមមិញគេនិយាយបារាំងណ៎ា ខ្ញុំចាំមិនបាន ហើយគ្រួសារខ្ញុំនៅតាអីរតនគិរី នៅតាស្រុកមេមត់នោះឯង ។

ប៊ុនថន : អ្ហូ! គាត់ប្រចាំការនៅហ្នុង?

ម្ដាយ ដារ៉េត : ហើអត់ដឹងតាខ្ញុំមកសុំទេ សុំលួងអង្វរគេ ។ គេថាគេសុំបានណ៎ា ហើយលោកនោះបិតមាត់បិទកមិនឲ្យនិយាយសោះ ស្រាប់តែបានឈ្មោះធ្លាក់ទៅក៏ម្នាក់ៗទៅសួរខ្ញុំថា ធ្វើម៉េចបានឈ្មោះបកទៅក្រោយវិញ ។ ម៉េចបានឈ្មោះផ្លាស់ទៅថ្នូពួកវិញ! ថាខ្ញុំមិនដឹងផង ម៉ែខ្ញុំដឹងគាត់គិតគូរឲ្យខ្ញុំ ហើយខ្ញុំមកឆ្ងាយពីគាត់ណ៎ា! អត់ហ៊ានប្រាប់ទេ តាគាត់ប្រាប់ថា ចៅឯងកុំនិយាយតាជួយតែកូនឯងមួយទេព្រោះកូនឯងកូនច្រើនណាស់ ហើយដល់ពីនោះទៅបានសំបុត្របានធ្លាក់ទៅបានពីរថ្ងៃ ។ មានគេមកខ្ញុំផ្ញើទៅ ខ្ញុំផ្ញើសំបុត្រទៅគ្រួសារខ្ញុំ ។ គ្រួសារខ្ញុំស្ងួតណាស់ មិនចេះនិយាយចេះស្ដីអីទេ ។ ទាហានក៏ទាហានងាប់មួយកន្លែងហ្នឹងឯង ។

ប៊ុនថន : ផ្ញើទៅតាមពីណាសំបុត្រហ្នឹងអ៊ី?

ម្ដាយ ដារ៉េត : ផ្ញើទៅតាមតែពួកទាហានគេមក ។

ប៊ុនថន : ទាហាន?

ម្ដាយ ដារ៉េត : គេមកយកអង្ករយកអីទៅណា ហើយខ្ញុំផ្ញើទៅ ។ ខ្ញុំផ្ញើទៅក៏គេឲ្យសំបុត្រគ្រួសារខ្ញុំទៅក៏ថា អ្ហែ៎ង! ទៅរកស្រួលតែឯងឲ្យអញកម្មវេទនានៅតែ ពួកអញនៅក្នុងព្រៃនេះ

អាណាចិត្តល្អអញមិនឲ្យទៅទេថាណោះ មេគេណោះ អញមិនទៅទេ។ ហីគាត់មកនិយាយប្រាប់ខ្ញុំថា គាត់ថា អ្ហឺ! មានសំបុត្រត្រឹមត្រូវហើយគាត់ទម្លាក់កាំភ្លើងទុកឲ្យគេហើយ យកក៏មិនយកហី។ គាត់ក៏ឡើងឡានទាហានមកណោះ ឡានគេទៅមកដឹកអន្តរជញ្ជូនស្បៀងទៅណា។ ចា៎!

ប៊ុនថន : គាត់មកពីណាវិញកាលហ្នុង?

ម្ដាយ ដារ៉េត : មកពីរតនគិរី។

ប៊ុនថន : អ្ហូ! គាត់ទៅដល់រតនគិរី?

ម្ដាយ ដារ៉េត : ចា៎! នៅរតនគិរី។ ដល់មកខ្ញុំផ្លាស់មកបានចំនួនពីរថ្ងៃ អ្ហឺក៏រត់ប្រហារនៅនោះ។ វាយគ្នា ដេញសាប់នៅក្បែរទន្លេ។ ស្អីកាលណា កាលឆ្នាំ៧០គត់នោះណា៎!

ប៊ុនថន : វាយជាមួយខាងណាអីកាលហ្នុង?

ម្ដាយ ដារ៉េត : ដឹងជាវាយជាមួយខាងណា ពួកគេវាយគុងក្ដាំង១ទៅខ្ញុំមកនៅនេះហើយ ពួកតែសូរវាយ។ ហីមានបងខ្ញុំមួយ ដីដូនមួយគាត់នៅនោះដែល បែកប្រពន្ធបែកកូន រត់ព្រព្រោងព្រព្រាត។ ប្រពន្ធទៅផ្សេង ប្ដីទៅផ្សេងឲ្យតែបានរស់។ បើរស់ទៅ គាត់ទៅនៅណាធីកាលទៅនៅបាក់រនាស់។ គាត់ឡើងទៅលើក៏ដឹងថាប្ដីនៅរស់ ប្រពន្ធក៏ទៅតាមថាប្ដីចុះមកហើយ ធ្វើទាហានទៀត១។

ប៊ុនថន : ធ្វើទាហានខាង លន់ នល់?

ម្ដាយ ដារ៉េត : ចា៎! ទេយើង៧៩ហើយអី។

ប៊ុនថន : ៧០គត់រដ្ឋប្រហារ?

ម្ដាយ ដារ៉េត : ចា៎! ៧៩ហើយដែលគាត់ឡើងទៅលើ។

ដារ៉េត : ៧៩ វៀតណាមចូលទេ។ ៧៩ វៀតណាមចូល ៧៨។

ម្ដាយ ដារ៉េត : អ្ហឺ!

ប៊ុនថន : ៧៨?

ម្ដាយ ដារ៉េត : អ្ហ៎ឺ!

ដារ៉េត : ៧៨ វៀតណាមចូលពុកសាប់។

ប៊ុនថន : ចោះគ្រួសារអ៊ំឈ្មោះអីវិញអ៊ំ?

ម្ដាយ ដារ៉េត : ធន់ ធីម។

ប៊ុនថន : ហីចោះគាត់មកពីខាងរតនគិរីហ្នឹងគាត់ទៅណាវិញអ៊ំ?

ម្តាយ ដារ៉េត ៖ ហើគាត់មកបានសំបុត្រមកក៏គាត់មកៗដល់កន្លែងខ្ញុំ មកដល់កន្លែងបន្ទាយអ្នកលឿង នេះចំនួនម៉ោងបីៗ គាត់ថា ចោះយើងទៅទាំងល្ងាចនេះឯង ថាចេះៗ គ្រែ ពាង ស្អីៗក៏អត់គិតដែរ អរណាស់ៗ គាត់អរណាស់ បានមកជួបម្តាយៗ ហើគាត់អរណាស់ ក៏បានមកទាំងយប់ហ្នឹងឯងៗ មកទៅក៏ដល់ មកនៅថ្មពួកបានប្រាំឆ្នាំក៏អាពតចូល អាពតចូលក៏វែកកូនមក កង់ ម៉ូអីគេយកអស់ៗ ហើវែកកូនមក ដាក់សង្រែកវែកមីនេះមកដើរៗ

ប្រុញ ៖ ប្តីអ្នកមីងមកនៅណាវិញអ្នកមីង?

ម្តាយ ដារ៉េត ៖ ចា៎!

ប្រុញ ៖ នៅ?

ម្តាយ ដារ៉េត ៖ មកទាំងអស់ៗ

ប្រុញ ៖ នៅអ្នកលឿង?

ម្តាយ ដារ៉េត ៖ ចា៎! នៅអ្នកលឿងកាលដែលខ្ញុំសុំផ្លាស់មកនៅអ្នកលឿង សុំផ្លាស់មកនៅថ្មពួកវិញៗ

ប្រុញ ៖ អូ! ចឹងការពិតទៅអ្នកមីងអត់នៅថ្មពួកទេ នៅអ្នកលឿង ដល់ពេលខ្មែរក្រហមចូលហើយបានគេឲ្យអ្នកមីងមកថ្មពួកវិញ?

ម្តាយ ដារ៉េត ៖ អត់ទេកាលពេលរដ្ឋប្រហារៗ

ដារ៉េត ៖ កំពុងតែច្បាំងៗ

ប៊ុនថន ៖ កំពុងតែច្បាំងអ៊ីប្រុសផ្លាស់មកហ្នឹងគាត់ស្នាក់នៅអ្នកលឿងសិនមែនទេ?

ម្តាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ គ្រាន់តែមួយរយៈពីរថ្ងៃ?

ម្តាយ ដារ៉េត ៖ អត់ទេមកស្នាក់នៅហ្នឹងស្វាយហ្នឹងឯងៗ នៅមកផ្ទះខ្ញុំហ្នឹងឯង បានពីរថ្ងៃនោះរដ្ឋប្រហារៗ ស្អែកឡើង បានពីរយប់បានទៅថ្មពួកៗ

ប៊ុនថន ៖ កាលហ្នុងផ្ទះអ៊ីនៅណា?

ម្តាយ ដារ៉េត ៖ ខ្ញុំនៅហ្នឹងកន្លែងនេះឯងៗ

ដារ៉េត ៖ កាលនោះណា៎!

ប៊ុនថន ៖ កាលហ្នុងពីដើមណា ស្រុកកំណើតអ៊ីពីដើម?

ម្តាយ ដារ៉េត ៖ នៅនេះឯងៗ

ប៊ុនថន ៖ នៅនេះ?

ម្តាយ ដារ៉េត ៖ ចាំ! នៅប៉ោយព្រីង ភូមិប៉ោយព្រីង ព្រះនេត្រព្រះ ។

ប៊ុនថន ៖ បាទ?

ម្តាយ ដារ៉េត ៖ ប្តីខ្ញុំបាននៅភូមិតាប៉ែន ភូមិឯមុខនោះ ។

ប៊ុនថន ៖ ហើចឹងអ៊ីប្រុសមកពីរតនគិរីហ្នឹងគាត់ស្នាក់នៅអ្នកលឿងសិន បានគាត់មកស្វាយនេះ?

ម្តាយ ដារ៉េត ៖ ថាមកដល់ម៉ោងបី ចេញមកម៉ោងបីគាត់អរណាស់ បានផ្លាស់មកនេះ ។ មកតាំងម៉ោងបីមកទាំងយប់ ភ្លឺឡើងដល់បាត់ដំបង ។ ហើឡានវាខូច កុំឡានវាខូចបានដល់ទាំងយប់ ។ ភ្លឺឡើង ថ្ងៃរះដល់បាត់ដំបងដល់នេះមកនៅហ្នឹងស្វាយហ្នឹង ផ្ញើអីវ៉ែអីវ៉ាន់គេខ្ញុំផ្ញៀតមកលេងម៉ែពុកនៅភូមិ ។ មកលេងបានពីរយប់បានខ្ញុំត្រឡប់ទៅថ្មពួកវិញ ។

ប៊ុនថន ៖ ថ្មពួក?

ម្តាយ ដារ៉េត ៖ ចាំ! ទៅនៅថ្មពួកបានប្រាំឆ្នាំបានអាពតចូល ។ អាពត ចូលក៏វែកកូនមកតាំងពីថ្មពួកមកដល់នេះសុទ្ធតែដើរ ។ មីនេះដើរតាមយំមិនដឹងធ្វើម៉េច ខ្ញុំវែកសម្រែកដងវែកដាក់ចានដែកមួយ ដាក់អង្ករ ខោអាវកូន ។ គាត់នៅអូសកង់កញ្ចាស់មួយមានប្អូនមួយទៀត នោះដើរអត់រួច ខ្ញុំដើររួចចេះតែឲ្យដើរតិចៗ ។ ស្រាប់តែពីនោះមកដល់ភាស ។ ខ្ញុំទម្ងន់មីមួយនៅអាយធំពីខែនៅក្នុងពោះទៀត ហើយវាចាញ់កូនដងមកដល់ផ្ទះខ្ញុំដួលព្រួស ។

ប៊ុនថន ៖ ដើរមកពីហ្នុងមកអី?

ម្តាយ ដារ៉េត ៖ ចាំ! ខ្ញុំដួល ។ គេចូលភូមិអស់គ្រប់គ្នា ហើយខ្ញុំទើបនឹងរួច ដល់ប្តីយកកូនទៅទុកសិនយកអីវ៉ាន់ទៅទុកសិនបានឲ្យអាកូនប្រុសមួយអាយុប្រហែល២០រៀននៅស្វាយ ។

ដារ៉េត ៖ អាននោះងាប់និរសារ តាមង តាវ៉ាល់ នោះ!

ម្តាយ ដារ៉េត ៖ ងាប់នោះឯង ។ វាទៅយកខ្ញុំ អីវ៉ាន់ខ្ញុំវែកហ្នុង ហើយកាននោះគ្រាខ្ញុំមកនៅហ្នឹងផ្ទះគេមកដល់មិនដឹងអីណាបាយកូនមិនដឹងអីណាបាយប្តីទេ ។ ធ្វើអត់កើតទេខ្ញុំហ្នឹងវាអស់ហើយ ដើរខ្សោយ អស់ដៃអស់ជើងហើយ ។ ដាំបាយឲ្យកូនអីក៏មិនបានហូបៗក៏ខ្ញុំដេក គេឲ្យខ្ញុំដេកទៅ ។ ប៉ាវាក៏ដាំបាយដាំអីឲ្យកូនហូប ដល់នេះដាស់ឲ្យខ្ញុំហូប ខ្ញុំហូបអត់រួច លេបអត់រួច វាហេវវាសោះអស់ ហើយខ្ញុំក៏ចេះតែដេកទៅ ។ ដេកៗដល់ព្រឹកឡើងមានកម្លាំងៗគេក្រោកពីព្រលឹម ក៏បានវែកអម្រែកដងវែកមកទៀតមកដល់ឈ្នួរបានដាំបាយព្រឹកហូប ។

ប៊ុនថន ៖ ឥឡូវឈ្នួរ?

ម្ដាយ ដារ៉េត ៖ ចា៎! ឃុំឈ្នួរនេះ ៗ ដល់ភូមិឈ្នួរ ស្រាប់តែដល់ភូមិឈ្នួរហើយនេះ ដាំបាយអីហូបរួចបាននាំគ្នាដើរមកដល់ព្រះនេត្រព្រះហ្នឹងបានមកដល់ ៗ ឡើងល្ងាចម៉ោងប្រាំបានដល់ផ្ទះ ៗ មិនទាន់មែនទែនទេ នៅសំណាក់នឹងគេនៅហ្នឹងជើងវត្ត ឲ្យអ្នករទេះ ៗ

ប៊ុនថន ៖ នៅជើងវត្តណាអ៊ំ?

ម្ដាយ ដារ៉េត ៖ នៅជើងវត្តកន្ទែងបៀតសាលាឃុំ ៗ សំណាក់នៅនោះឯង ឲ្យកូនមកយកក្រែងមានរទេះមានគោអី ៗ ស្រាប់មកយករទេះយកគោ ជម្លៀសម៉ែខ្ញុំចុះទៅក្រោមអស់អត់មានណានៅទេ ៗ

ប៊ុនថន ៖ ម្ដាយអ៊ំជម្លៀសទៅណាវិញទៅស្រែះ?

ម្ដាយ ដារ៉េត ៖ ទៅស្រែះ ចា៎!

ប៊ុនថន ៖ ចឹងអ៊ំធ្វើដំណើរពីហ្នឹងប៉ុន្មានថ្ងៃបានមកដល់នេះ?

ម្ដាយ ដារ៉េត ៖ មកពីថ្មពួកដេកនៅយាមវេនមួយ មកដេកនៅផ្ទះមួយយប់ បីយប់បានដល់ ៗ

ប៊ុនថន ៖ បីយប់?

ម្ដាយ ដារ៉េត ៖ បីយប់ ៗ

ប៊ុនថន ៖ ស្នាក់នៅយាមវេន?

ម្ដាយ ដារ៉េត ៖ ស្នាក់នៅយាមវេន ភាស ៗ ដេកភាសមួយយប់ ដេកនៅយាមវេនមួយយប់ ហើយក្រោកមកដល់ណោះមួយទៀតវាបី ៗ

ប៊ុនថន ៖ បីយប់បានដល់?

ម្ដាយ ដារ៉េត ៖ បីយប់ត្រឹម ៗ

ប៊ុនថន ៖ ដើរតែម្ដង ឬក៏មានកង់អីជិះអ៊ំ?

ម្ដាយ ដារ៉េត ៖ កង់ប្ដីខ្ញុំនៅសល់កង់កញ្ចាស់មួយ កង់មួយនោះកូនទៅរៀននៅស្វាយហីក៏ ៗ វាអស់លុយទៅសុំលុយខ្ញុំមករៀនទៀត ទុកកង់ចោល ៗ អាបងនោះក៏ដើរ មីនេះក៏ដើរ ខ្ញុំរែកអីវ៉ាន់ រែកអង្ករ រែកខោអាវកូនដើម្បីដាំបាយហូបតាមផ្លូវ ៗ

ប៊ុនថន ៖ ចឹងកូននៅស្វាយរៀនម្នាក់ហ្នុងក៏មកជាមួយអ៊ំដែរ?

ម្ដាយ ដារ៉េត ៖ ចា៎! មកជាមួយ ៗ

ប៊ុនថន ៖ ជួបគ្នានៅណាវិញ ជួបនៅស្វាយ?

ម្ដាយ ដារ៉េត ៖ ជួបគ្នានោះឯង កូនវាទៅយកលុយថ្មពួកណា៎! យកពីខ្ញុំ ជួបថ្មពួកនោះក៏មកទាំងអស់គ្នា ៗ

ប៊ុនថន ៈ ចឹងដើរមកទាំងអស់?

ម្ដាយ ដារ៉េត ៈ ចាំ! ដើរមកជាប់ មកនៅជុំគ្នា ។ ដល់គេជម្លៀស មកដល់ពីរយប់ប៉ុណ្ណោះឯង ។ គេជម្លៀសទៅស្រែះដែរ ។ ដល់ទៅលោកគ្រូអើយ ហ៊ីខ្ញុំកាលនោះខ្ញុំក្មេងណាមិនទាន់ដឹងអីទេ ។ ដល់ទៅក៏ឃើញខ្មោចគេសែង ខ្មោចដែលគេវាយមុនខ្ញុំទៅណាំ! ឃើញតាមផ្លូវគេសែងដាក់អន្ទុងណាំ! មិនដឹងអីសោះ ប៉ាវ៉ាៗឯងមើល កាលនោះហៅប៉ាម៉ាក់ហ្នឹងណាំ! ថាពួកអស់នោះទំរាំបានម៉ែហៅពុក មូលកូនឡើងដាំភ្លៅ ។

ដារ៉េត ៈ មូលទាល់តែលែងហៅម៉ែកើត ។

ម្ដាយ ដារ៉េត ៈ ដល់ឃើញគេសែងមនុស្សដាក់អន្ទុងបានយើងហៅថាប៉ាវ៉ាៗ ឯងមើលគេសែងគោ ។ ដល់គាត់ដឹងនោះ គាត់មុខឡើងស្រកអស់ អីកុំមាត់ដើរឲ្យលឿនៗ ។

ប៊ុនថន ៈ កាលហ្នឹងច្រើនទេអី ឃើញគេសែងខ្មោចច្រើនទេ?

ម្ដាយ ដារ៉េត ៈ ខ្មោចលោក រឺ នៅភូមិប៉ោយសំរោងហ្នឹងឯង ។ ទាំងប្ដីទាំងប្រពន្ធហ្នឹង ។

ដារ៉េត ៈ គេសម្លាប់ម៉ាគ្រួសារ ។

ម្ដាយ ដារ៉េត ៈ ខ្ញុំក៏ដើរកាត់ នាំកូនដើរកាត់ចេះ ។

ប៊ុនថន ៈ ម៉េចបានគេវាយគ្រួសារគាត់ រឺ?

ម្ដាយ ដារ៉េត ៈ គាត់មេទាហាន ដឹងយ៉ាងណាបានគេវាយ ។ ខ្ញុំដើរដែរនៅស្រុក ដើរនៅតែតាមខេត្តតាមប្ដី ដែលបាននៅស្រុកនៅស្រែបានដឹងនឹងគេទេ ។ ប៉ុនខ្ញុំអត់ដឹងអីក៏ខ្ញុំថា គេសែងគោៗ ដឹងគេសែងមនុស្ស ។ ខ្ញុំមិដឹងក៏ខ្ញុំថា គេសែងគោប៉ាវ៉ាមើលគេសែងគោ ។ អ្ហូ! ដើរឲ្យលឿនមកៗ មើលទៅមុខនៅប៉ោយព្រីង ។

ប៊ុនថន ៈ ចុះកាលហ្នឹងអីប្រុសគាត់នៅស្លៀកពាក់ខោអាវទាហានអីដែរ?

ម្ដាយ ដារ៉េត ៈ អត់ទេ ។ ស្លៀកពាក់ខោអាវស៊ីវិលចេះ កប់អស់ ។ រូបថតក៏នៅផ្ទះដែលនេះពាក់ស័ក្តិពាក់អីហ្នឹង ។ បងប្អូនឡើងទៅលើផ្ទះខ្ញុំ គេឃើញគេយកទៅកប់យកទៅដុតអីអស់រូបថតរូបអី ។

ប៊ុនថន ៈ ចឹងគាត់ដឹងខ្លួនដែរនិយាយថា ទាហាន លន់ នល់ គេធ្វើបាបធ្វើអីចឹង?

ម្ដាយ ដារ៉េត ៈ គាត់ដឹងគាត់ដែរនិយាយប្រាប់ខ្ញុំ ។ គាត់ដឹងដែរក្នុងចិត្តគាត់ គាត់ដឹងហើយបានគាត់មិនដែលហ៊ាននិយាយប្រាប់ខ្ញុំទេ រឿងអីយ៉ាងណាក៏គាត់មិនដែលនិយាយប្រាប់ដែរ ។ ទៅអុបប៉េណាពីរបីខែក៏គាត់មិនដែលនិយាយប្រាប់ខ្ញុំ ស្រាប់តែថាម៉ាក់វារៀបអីវ៉ាន់

ឲ្យខ្ញុំក៏រៀបឲ្យទៅ រៀបខោអាវអីឲ្យទៅ។ ដែលនិយាយប្រាប់ខ្ញុំថារឿងចេះរឿងចុះអី អត់ទេ។

ប៊ុនថន : អត់ដែលនិយាយប្រាប់អឺរឿងការងារអី?

ម្ដាយ ដារ៉េត : អត់ដែលសោះ។ គាត់មិនដែលនិយាយទេ រឿងការងារទៅណាទៅណីអត់។ កាលមុននេះផ្លាស់ទៅបន្ទាយលង្វែកម្ដង គ្រូអើយសំណាងល្អ។ ខ្ញុំមួរលុយៗនោះនៅសល់ប្រាំពីរពាន់ ប្រាំពាន់យើងពីដើមអាក្រដាសក្ហមណា៎!

ប៊ុនថន : បាទ! ថ្ងៃណាស់អឺលុយសម័យហ្នឹងប្រាំពីរពាន់?

ម្ដាយ ដារ៉េត : ចា៎! លុយសម័យប្រាំពីរពាន់ឯង។

ប៊ុនថន : អូ! សម័យ លន់ នល់ លុយក្ហម?

ម្ដាយ ដារ៉េត : លុយសម័យ លន់ លន់ មិនសម័យចា៎!

ប៊ុនថន : ថ្ងៃណាស់អឺប្រាំពីរពាន់?

ម្ដាយ ដារ៉េត : ទេដូចជាមិនមានតម្លៃប៉ុន្មានទេ។ មានប្រាំពីរពាន់នោះជិះកប៉ាល់ហោះទៅពីហ្នឹងឯងបាន ដល់គ្រន់អាសណ្ដោងអាគេមួយផង រត់តាមផងមិនដឹងធ្វើម៉េចអត់ អស់ត្រឹមបាត់ដំបង។

ប៊ុនថន : បន្ទាយលង្វែកអឺ?

ម្ដាយ ដារ៉េត : ចា៎! គាត់រត់។ កំពុងតែដាំៗទឹកក៏ ទឹងមកក៏អស់ម្នាក់ពីរនាក់ គាត់ក៏គេចផុតទៅ។ ដល់គេសាប់មែនទែនអាកាំភ្លើងគេបាញ់មកច្រើន ម្នាក់ក៏រត់ទៅកើត ម្នាក់ក៏រត់ទៅលិច គាត់រត់មកភ្នំពេញ។

ប៊ុនថន : បាទ! រត់មកភ្នំពេញ?

ម្ដាយ ដារ៉េត : ចា៎! រត់មកភ្នំពេញមកពោធិចិនតុង ក៏គាត់មានលុយខ្ញុំដាក់ទៅឲ្យ។ ណា៎! មានលុយនៅស្រោមកគាត់ខ្ញុំដាក់ទៅឲ្យប្រាំពីរពាន់ក៏គាត់ទិញសំបុត្រកប៉ាល់ហោះជិះមក។ ណា៎! ជិះតែគាត់បានហើយម៉ាសោហ៊ុយគាត់ តែម្នាក់នោះសុំដោយសារមកផង។

ប៊ុនថន : ម្នាក់ណាអឺ?

ម្ដាយ ដារ៉េត : ទាហានដូចគ្នា តែគាត់ក្មេង។ គាត់ចាស់ហើយចំណាស់អាយុ៣៧-៣៨ហើយគាខ្ញុំ។ ណា៎! អ្នកក្មេងនោះប្រហែលជាទំនប់អាយុ២០។

ប៊ុនថន : ហីបានមកទេបើសំបុត្រតែម្នាក់ចឹង?

ម្ដាយ ដារ៉េត ៖ សុំគេនេះមកថា មកដល់បាត់ដំបងមកដល់មង្គលបុរីចាំបងប្អូននៅមង្គលបុរីចុះខ្ចីគេឲ្យ ។ អាមួយនោះសុំលើកដៃសំពះទៅណា បើថាលុយខ្ញុំមានតែប៉ុណ្ណឹះទេ សុំអាមួយនេះទៅដោយសារជង់ទៅបានដែរក៏អត់ ។ មកដល់បាត់ដំបងវាស្គាល់គេនោះ សុំបានតែម៉ាគ្រប់ ដល់ជិះពីបាត់ដំបងមកមង្គលបុរីនេះអត់មានមួយរៀលសោះ ។ អត់រលីងបានអាមួយដែលសុំដោយសារមកជង់នោះហើយទៅសួរ សុំបងប្អូនគាត់ដែលនៅមង្គលបុរី ចាំ! បានវាឲ្យប៉ុន្មានរយមកទេ បានជិះឡានពីមង្គលបុរីមកដល់ស្វាយសិសុផុន ចាំ! មកដល់ផ្ទះខ្ញុំព្រះនេត្រព្រះអស់ ។ ទៅវិញប្អូនសុំម៉ែទៅថ្មពួកទៀតអស់លុយ ។

ប៊ុនថន ៖ ចឹងជិះកប៉ាល់ហោះមកបាត់ដំបង ហើយពីបាត់ដំបងមក?

ម្ដាយ ដារ៉េត ៖ ពីបាត់ដំបងជិះឡាន ។

ប៊ុនថន ៖ ជិះរហូតដល់ស្វាយ?

ម្ដាយ ដារ៉េត ៖ ជិះរហូតដល់ស្វាយ ។ ដល់នេះគាត់ចូលលេង តែខ្ញុំនៅថ្មពួកណោះ ។ ខ្ញុំនៅថ្មពួក គាត់ទៅតែគាត់ ។

ប៊ុនថន ៖ កាលនោះឆ្នាំប៉ុន្មានដែលអឺប្រុសគាត់រត់មក?

ម្ដាយ ដារ៉េត ៖ ខ្ញុំវាវង្វេងវង្វាន់អស់ហើយសព្វថ្ងៃនេះ ។

ប៊ុនថន ៖ ៧០ រដ្ឋប្រហារហើយអឺ?

ម្ដាយ ដារ៉េត ៖ ចាំ! រដ្ឋប្រហារហើយ ។

ប៊ុនថន ៖ រដ្ឋប្រហារហើយប៉ុន្មានឆ្នាំអឺ?

ម្ដាយ ដារ៉េត ៖ មើល៧៥បាននេះចូល ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ ប្រហែលជា៧៣ ។ ចាំ! ឆ្នាំ៧៣ ។

ប៊ុនថន ៖ ហើគាត់រត់មកទៅថ្មពួកអឺ?

ម្ដាយ ដារ៉េត ៖ ចាំ! ទៅខ្ញុំថ្មពួក ។

ប៊ុនថន ៖ កាលនោះគាត់ផ្លាស់មកពីរតនគិរីមកហើយ?

ម្ដាយ ដារ៉េត ៖ ចាំ! មកហើយមកពីឆ្នាំ៧០ មកឆ្នាំ៧០ ។

ប៊ុនថន ៖ ចោះមកពីអ្នកលឿងមក ពីអ្នកលឿងមកឆ្នាំប៉ុន្មានអឺ?

ម្ដាយ ដារ៉េត ៖ ពីអ្នកលឿងឆ្នាំ៧០គត់ដែរ ។

ប៊ុនថន ៖ ពីរតនគិរីហើយបានមកអ្នកលឿង បានពីអ្នកលឿងហើយបានមកថ្នូកវិញ?

ម្ដាយ ដារ៉េត ៖ ចា៎! គាត់មកជូនគ្នាហ្នឹងឯង មកពីរតនគិរីចំនួនម៉ោងបីបានដល់អ្នកលឿង។ គាត់ឲ្យខ្ញុំមកទាំងយប់ ជួលម៉ូតូអីគេដឹកមកចម្លងអ្នកលឿង ចម្លងស្រឡាង។

ប៊ុនថន ៖ ចេញមកតែអ៊ឹ គាត់នៅហ្នុងមួយរយៈសិនក៏មកទាំងអស់គ្នា?

ម្ដាយ ដារ៉េត ៖ មកទាំងអស់គ្នាទាំងកូនទាំងអី មកទាំងអស់។

ប៊ុនថន ៖ កាលហ្នុងម៉េចអត់ទៅតាមកំពង់ចាមអ៊ឹ?

ម្ដាយ ដារ៉េត ៖ ទៅឯណាបើស្រុកស្រែវាអត់ស្រួល។ ទៅតែប្ដីៗ ទៅអុបប៉េលោកគ្រូ។

ប៊ុនថន ៖ ចឹងមកកាត់តាមអ្នកលឿងវិញ?

ម្ដាយ ដារ៉េត ៖ ចា៎! ខ្ញុំបន្ទាយសឹបនៅអ្នកលឿងលោកគ្រូ។ ហីគេយកប្រពន្ធទៅដាក់អ្នកលឿងហើយប្ដីៗគេបញ្ជូនទៅអស់។

ប៊ុនថន ៖ អ្ហូ! បន្ទាយធំនៅហ្នុង?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ ហីបន្ទាប់ពីអ៊ីប្រុសមកពីនេះហើយ រត់មកពីលង្វែកហើយគាត់នៅធ្វើការដដែលអ៊ឹ?

ម្ដាយ ដារ៉េត ៖ ចា៎!នៅធ្វើការដដែល។

ប៊ុនថន ៖ ចោះគាត់រត់ចឹងគេអត់ថាអីទេអ៊ឹ?

ម្ដាយ ដារ៉េត ៖ អត់ថាអីទេ។ គេទទួលយកគេអរទៀត ព្រោះអីវាច្បាំងណាស់ វាយគ្នាណាស់កាលហ្នុង។ បានរស់មក មានអីលោកខេត្តលោកអរ។

ប៊ុនថន ៖ កាលហ្នុងពីណាខេត្តអ៊ឹ?

ម្ដាយ ដារ៉េត ៖ លោកអ្នក ស៊្វី សារឿង ទៅណា។

ប៊ុនថន ៖ ខេត្តអ៊ឹ?

ម្ដាយ ដារ៉េត ៖ មិនចាំទៅណា៎! លោកស៊្វី សារឿន ទៅណា៎!

ប៊ុនថន ៖ អភិបាលខេត្តកាលហ្នុង?

ម្ដាយ ដារ៉េត ៖ លោកខេត្ត ខេត្ត។

ប៊ុនថន ៖ បាត់ដំបងហ្នឹង?

ម្ដាយ ដារ៉េត ៖ អ្ហ៎! ខេត្ត។

ដារ៉េត ៖ ខេត្តបាត់ដំបងពីដើមមិញ។

ម្ដាយ ដារ៉េត ៖ ខេត្តសឹបណា៎!

ប៊ុនថន ៖ បន្ទាយសឹប?

ម្ដាយ ដារ៉េត ៖ បន្ទាយសឹប។ ចា៎! មានខេត្តមួយ មានលោកខេត្តមួយ។

ប៊ុនថន ៖ បន្ទាយសឹបនៅថ្មពួកអី?

ម្ដាយ ដារ៉េត ៖ ចា៎! បន្ទាយសឹបនៅថ្មពួក។

ប៊ុនថន ៖ គាត់ឈ្មោះអីអី?

ម្ដាយ ដារ៉េត ៖ ខ្ញុំភ្លេចទៅ។ ណា៎! ស៊ី សារឿន ណាទេ។ សេត សារឿន ខ្ញុំភ្លេចហើយលោកគ្រូ អើយយូរហើយ។

ប៊ុនថន ៖ នៅម្ដុំថាថ្មពួកអីបន្ទាយគេកាលហ្នឹង ឥឡូវ?

ម្ដាយ ដារ៉េត ៖ ម្ដុំគេហៅស្វាយជ្រុំលោកគ្រូ។

ប៊ុនថន ៖ ស្វាយជ្រុំ?

ម្ដាយ ដារ៉េត ៖ ចា៎! ទៅអាកន្លែងស្វាយច្រើន អាកន្លែងស្វាយច្រើននៅខាង។

ប៊ុនថន ៖ ខាងណាផ្សារ?

ម្ដាយ ដារ៉េត ៖ ខាងជើងថ្មពួក។ នៅជើងស្រុកថ្មពួក។

ប៊ុនថន ៖ ខាងជើងទីរួម សាលាស្រុកអី?

ម្ដាយ ដារ៉េត ៖ ចា៎! ទៅ។

ប៊ុនថន ៖ ខាងជើងសាលាស្រុក?

ម្ដាយ ដារ៉េត ៖ ចំនួនប្រហែល៥០០ម៉ែត្រដល់។

ប៊ុនថន ៖ ហើម៉ាបន្ទាយហ្នឹងទ័ពច្រើនទេអី?

ម្ដាយ ដារ៉េត ៖ ម៉ាបន្ទាយទ័ពច្រើនណាស់លោកគ្រូ។

ប៊ុនថន ៖ ប្រហែលប៉ុន្មាននាក់អី?

ម្ដាយ ដារ៉េត ៖ សួរខ្ញុំអ្នកមិនដឹងទៅទៀតព្រោះ។ ច្រើនណាស់ ប្រហែលពីររយនាក់មិនដឹង។ លោកគ្រូថាស្មានទៅខ្ញុំមិនបានដឹងអស់។

ប៊ុនថន ៖ បាទ! ពីរយនាក់?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ កាលនោះប្រាក់ខែអីបានប៉ុន្មានអីដូចថាផ្គត់ផ្គង់គ្រួសារគ្រប់ទេកាលហ្នុង?

ម្ដាយ ដារ៉េត ៖ ចា៎! ដែលមិនសូវចេះលេងចេះសើចដូចខ្ញុំចេះតែគ្រប់នោះឯង ប្រាក់ខែ។

ប៊ុនថន ៖ ទាហានកាលនោះច្រើនដែរអី?

ម្ដាយ ដារ៉េត ៈ ចា៎! បានប្រាក់ខែកូនៗ ប្រាំពីរនាក់ ។

ប៊ុនថន ៈ កូនប្រាំពីរនាក់?

ម្ដាយ ដារ៉េត ៈ ខ្ញុំបានប្ដីមេម៉ាយនោះអ្ហ៎ា! ខ្ញុំអាយុ២៣ក៏ការនឹងគាត់ ។ និយាយពីប្រវត្តិវាវែងឆ្ងាយណាស់ ។

ប៊ុនថន ៈ ចឹងគាត់ទាំងអស់ប្រាំពីរនាក់?

ម្ដាយ ដារ៉េត ៈ ចា៎! កូនប្រាំពីរនាក់ ។ បានកូច្រើនដងបានប្រាក់ខែមួយពាន់ប្រាំរយ ។

ប៊ុនថន ៈ ម្នាក់?

ម្ដាយ ដារ៉េត ៈ ចា៎! ទាំងឪទាំងឪពុក ។ ប្រាក់ខែមួយពាន់ប្រាំរយ មួយពាន់ប្រាំបីរយ ។

ដារ៉េត ៈ មាសមួយដីបីរយហា ។

ម្ដាយ ដារ៉េត ៈ មាសមួយបីរយហាសិប ។

ប៊ុនថន ៈ អ្ហូ! បានច្រើនដែរអី?

ម្ដាយ ដារ៉េត ៈ ចា៎! តែគាត់ឈឺ ។ ដល់ឆ្នាំប៉ុន្មានទេ គាត់ឈឺ ។ ឆ្នាំ៧៨ដឹង ឈឺអស់ប្រាំម៉ឺន ។ ហ្នុងដេកពេទ្យមង្គលបុរី យកមកដេកពេទ្យមង្គលបុរី ។ គាត់ជាងឈើ ឈូសចាំងៗជូនកាលគេឲ្យទៅអុបប៉េទៅវាយៗទៅ ។ បើនៅកន្លែងសិប់វិញ កន្លែងបន្ទាយវិញគេឲ្យធ្វើជាង ។

ប៊ុនថន ៈ គាត់ជាងឈើ?

ម្ដាយ ដារ៉េត ៈ ចា៎! ជាងឈើ ឈូសចាំងៗទៅបែបឈឺអាកន្លែងចំឆ្អឹងជំនីផុតនោះឯង ។ ឆ្អឹងជំនីផុតប៉ោងប៉ុណ្ណេះលោកគ្រូ កាលនោះខ្ញុំកូនភ្លោះ ។

ប៊ុនថន ៈ អ្ហូ! មានភ្លោះដែរ?

ម្ដាយ ដារ៉េត ៈ ចា៎! បន្ទាប់ពីនេះ នេះកូនខ្ញុំ ។ កូនភ្លោះពីរ ហើយចាស់ៗប្រាប់ថា អឹងឯងកើតកូនត្រូវប្រកបប្រសិទ្ធិទៅមីនាងអើយ ។ ដល់ប្រកបសិទ្ធិទៅដូចរន្ធកូនលើផ្ទះណាចៅហើយខ្ញុំអត់ជឿថាកូនខ្ញុំងាប់អស់ហើយ ។ កើតបានកន្ទះក៏ងាប់បាត់ មីមួយថាមួយបានដប់បីថ្ងៃ មីមួយបានដប់ប្រាំបីថ្ងៃ។ ងាប់អស់ហើយ អស់គ្រោះអស់នាមហើយយាយអើយ ។

ប៊ុនថន ៈ កូនស្រីទាំងពីរ?

ម្ដាយ ដារ៉េត ៈ ចា៎! ស្រីទាំងពី ។ ស្រាប់តែដល់អត់ជឿគាត់លោកគ្រូឯង ដល់អស់ឡើងប្រាំម៉ឺនប្រាក់ខ្ញុំសន្សំ ។ ដេញតុងទីន មិនទាន់ដេញទេនៅបីក្បាល ហីប្រាក់ដែលខ្ញុំសន្សំយក

មកផ្ញើនឹងម៉ែខ្ញុំប្រាំពីពាន់ផ្ញើនៅមីប្អូន ហើយប្រាក់ខែនៅណោះនៅម្ដាយខ្ញុំពីរម៉ឺន ហីនោះដេញតុងទីនបីក្បាលទៀត ។ លោកគ្រូអើយមកយកណោះ យកទៅទាំងអស់ហី ប្រាក់ខែក៏បើកផង ហីប្រាក់ដេញតុងទីនពីរបីក្បាលក៏ដេញអស់ មើលប្ដីឲ្យតែជា ។

ប៊ុនថន ៖ សម័យនោះលេងតុងទីនដែរអី?

ម្ដាយ ដារ៉េត ៖ លេង ។

ប៊ុនថន ៖ ម៉ាក្បាលប៉ុន្មានកាលហ្នុង?

ម្ដាយ ដារ៉េត ៖ លេងម៉ាក្បាលមួយរយ ម៉ាក្បាលពីររយអស់ តែហ៊ានលេងច្រើនទេ ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ អ្ហឺ! មានមួយក្បាលមួយពាន់មួយ ។ នោះជិតកើបហើយ នៅសល់តែបីនាក់ក៏កើប ទៅ ។ ទទួលប៉ាវាឈឺយកទៅមើល សរុបទៅអស់ប្រាំម៉ឺន ។ ខ្ញុំអត់ដឹងលោកគ្រូអើយ ខ្ញុំអត់ដឹងពេទ្យនោះចិញ្ចឹមលុយណ៎ា! ស៊ីលុយអី ខ្ញុំពាក់ខ្សែដៃ ចិញ្ចៀននោះពីរវង់ ក្រវិលខ្សែករពីរខ្សែ ប្រាក់នោះនៅពីរបីម៉ឺននៅនឹងហោប៉ៅ ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ ផ្ញើអកដូណង់ម្ដងអស់ប្រាំបីពាន់ទៅទិញថ្នាំឲ្យលេប នៅតែដដែល ។ ផ្ញើម្ដងទៀតអស់ ប្រាំពីរពាន់ទៀតយកមកលេបនៅតែដដែល ។ ផ្ញើម្ដងទៀតអស់ប្រាំពាន់ យកមក លេបតាដែល អាចាក់ក៏ចាក់ អាលេបក៏លេប អត់មានថាទៅគ្រាន់យ៉ាងណាទេអត់ ។ អស់ថ្នាំទៀត ថាលោកគ្រូពេទ្យអើយអស់ថ្នាំហើយ ។ គាត់ប្រាប់ថាអ្ហឺ! ទៅទិញថ្នាំ ទៅ អាហាងនោះកុំទៅទិញណ៎ា! ទៅទិញអាកន្លែងណាដែលគេលក់ គាត់បង្ហើបថា ទៅទិញនោះឯង អាជិតផ្សារអូរឫស្សី អ្ហូអ្ហឺ! វត្តឫស្សី ។

ប៊ុនថន ៖ វត្តឫស្សី?

ម្ដាយ ដារ៉េត ៖ ថាចេះ ទៅទិញនោះទៅ ។ ខ្ញុំក៏ទៅទិញតាមគាត់ទៅ ទៅទិញបីពាន់មកក៏អត់ ។ មើល ទៅវាស្បើយប្រាក់ហើយកាលនោះ ប្រាក់នោះប្រាំពីរពាន់ដាក់ហោប៉ៅ ។ ប៉ាវាបើ មិនជាទេ ប្រាក់អស់ហើយនេះអស់ហើយ មានតែលក់មាសថាចេះ មានតែលក់មាស ទៀតបើឯងមិនជា ។ លោកគ្រូអើយទៅដល់អស់អាប្រាំពីរពាន់ ទៅទិញទៀតអស់បី ពាន់ នៅសល់ពីរពាន់ក៏អត់ជា ។ អស់ថ្នាំទៀតប្រាប់គាត់ទៀត ណែទៅទិញអស់ពីរ ពាន់ អាពីរពាន់នោះក៏អត់ជា នៅសល់ប្រាក់ពីរយនៅក្រប៉ៅ ។ គាត់សរសេរអក

ដូណាង់ឲ្យទៅទិញទៀត គាត់ប្រាប់ថា អ្នកឯងទៅទិញណាហ្នឹង ថាទៅទិញតាមលោកគ្រូពេទ្យឯងប្រាប់ ។ អ្ហឺ! ហ្វាម៉ាស៊ីបៀតអាវត្តបុស្សី ។

ប៊ុនថន : វត្តបុស្សីនៅមន្គលបុរីនេះអី?

ម្ដាយ ដារ៉េត : ចា៎! មន្គលបុរីណោះ ។ អូនឯងទិញប៉ុន្មានដងហើយ គ្រូពេទ្យឯងឲ្យទៅទិញប្រាំដងហើយខ្ញុំទិញតែកន្លែងនោះហើយ ។ ម៉េចក៏អត់បាត់ ម៉េចបានគ្រួសារខ្ញុំអត់បាត់ស្បើយចេះលោកគ្រូ ។ អ្ហឺ! ដឹងទេ ចឹងទិញម្ដងទៀត សរសេរអកដូណាង់ឲ្យទៅទិញទៀត ។ លោកគ្រូអើយ និយាយពីខ្ញុំភ័យប្រាក់នៅប្រាំរយនៅហោប៉ៅហ្នឹងទៀតហើយ ប្រាក់នៅប៉ុណ្ណឹងធ្វើម៉េចទិញគ្រប់ ។ ដល់ស្រាប់តែដល់គាត់ ខ្ញុំទៅទិញគាត់ឲ្យដកដូណាង់ទៅទិញ ខ្ញុំទៅទិញដល់ខ្ញុំទៅទិញលោកគ្រូពេទ្យគាត់ឲ្យម្ភៃគ្រាប់ ។ គាត់ឲ្យដប់ពីរគ្រាប់មក លោកគ្រូពេទ្យអ្ហើយអស់ប៉ុន្មានហ្នឹង ។ អស់មួយរយម្ភៃហើយនាង អ្ហូ! និយាយពីខ្ញុំអរ គ្រូពេទ្យអើយ ហើយបានជាអាថ្នាំមួយរយម្ភៃនោះឯង ។ គ្រូពេទ្យនោះក៏សួរខ្ញុំទៀតថា ណែនាងអ្នកឯងនៅលុយប៉ុន្មាន លោកគ្រូអើយខ្ញុំអស់ហើយនៅសល់ប្រាំរយនៅហោប៉ៅ ។ ខ្ញុំត្រង់ណាស់ ។

ប៊ុនថន : ទិញកន្លែងដដែល?

ម្ដាយ ដារ៉េត : ចា៎! ទិញកន្លែងតាដែល ។ គាត់ឲ្យអកដូណាង់ទៅទិញទៅ គេឲ្យថ្នាំដប់ពីរគ្រាប់សាក ។ អស់ប៉ុន្មានដែរលោកគ្រូ អ្ហឺ! អស់មួយរយម្ភៃអ្នកៗ ខ្ញុំក៏អរនោះអរហើយ ។ ដល់យកថ្នាំនោះបានទៅដល់អ្នកឈឺនោះថា ប៉ាវាអើយថ្នាំនេះអស់តែមួយម្ភៃទេ ។ អានេះមុខតែពិបាកលក់មាសហើយ ថាអ្ហឺ! ដឹងធ្វើម៉េចអ្ហែងឲ្យតែជាទៅ ។ ស្រាប់តែដល់គាត់លេបទៅលោកគ្រូអើយ មើលថ្នាំយ៉ាងណាឲ្យខ្ញុំលេបមើល ខ្ញុំក៏ហុចមួយគ្រាប់ទៅ គេឲ្យលេបម្ដងមួយគ្រាប់ ។ ថាណែ ដល់លេបទៅមនុស្សដេកស្ដឹងណា៎! លេបចូលដល់ពោះប៉ុណ្ណោះឯងណា ម៉ាក់វាឯងធូរខ្លួនម៉្លេះគាត់នោះថា គាត់ធូរខ្លួនម៉្លេះថាលេបថ្នាំនោះទៅផ្សំដឹងអ្ហេ៎ះ! ឲ្យឈើច្រត់ខ្ញុំបន្តិចមើល ខ្ញុំក៏រើសមែកឈើបានប្រវែងនេះយកមកឲ្យ ។ គាត់ចុះពីលើគ្រែគាត់អង្គិលៗ គាត់ចង់តែដើរនោះ ។ គាត់ដូចដើររួច ម៉េចក៏ខុសពីសព្វដងម៉្លេះលេបថ្នាំនេះទៅ ដូចជាណា៎! ម៉ែឯងយកឈើខ្ញុំបន្តិចទៅខ្ញុំច្រត់ៗ បានខ្ញុំយកឈើបានក៏ឲ្យច្រត់ក៏ត្រឹបៗបន្តិចៗនោះដើរដល់ណោះអើយសូមមួយគ្រាប់ទៀតមក ។ គាត់អរណាស់ ចា៎!

ប៊ុនថន : គាត់ជាថ្នាំនោះ?

ម្ដាយ ដារ៉េត ៖ សុំមួយគ្រាប់ទៀតមក ។ ថាទេឈប់សិនចាំបានពីរម៉ោងសិន ឯងក៏ឆាប់លេបប្រទូន ប្រយ័ត្នរអោស្បុងថ្នាំ ។ យើស មួយគ្រាប់ទៀតមក ។ ខ្ញុំជិតបានពីរម៉ោងហើយ នៅមួយម៉ោងកន្លះ អ្ហឺ! លេបៗចោះខ្ញុំក៏ឲ្យទៀត ក៏ដើរភិលលោកគ្រូអើយលេបទើប អស់ពីរគ្រាប់ ។

ប៊ុនថន ៖ ថ្នាំអីវិញ?

ម្ដាយ ដារ៉េត ៖ លោកគ្រូអើយខ្ញុំភ្លេចទៅហើយ យូរណាស់ទៅហើយខ្ញុំមិនបានចាំទេ ។ អាំងហ្វាអីទេ អីត្រង់ណាទេគេហៅពាក្យបារាំង ។

ប៊ុនថន ៖ អាំងហ្វា?

ម្ដាយ ដារ៉េត ៖ ចាំ! ថ្នាំហ្នឹងគេហៅអាំងហ្វា ។ ដប់ពីរគ្រាប់មក លេបអស់បានបីគ្រាប់ក៏ថា អើយសុំពេទ្យៗទៅកន្លែងវិញ ។ សុំពេទ្យៗ ក៏គាត់បង្គាប់ៗខ្ញុំថាពេទ្យថាឲ្យសម្រាកការងារមួយខែ ។ ណ៎! ខ្ញុំក៏ទៅសុំតាមគាត់ទៅ ដល់ខ្ញុំមិនទាន់បានសុំប្រាប់ពេទ្យផង ពេទ្យគេធ្វើអាដេញរអោស្បុងឲ្យទៅបាត់ហើយ មកយកមកឲ្យបាត់ហើយ ។ បានមើលទៅថាឲ្យមួយខែសិនបានធ្វើការបាន ។ ណ៎! មិនបានសុំគាត់ផង ។

ប៊ុនថន ៖ ចឹងកាលនោះគេអត់មានចេញលុយឲ្យទេពេលឈឺ?

ម្ដាយ ដារ៉េត ៖ អត់មានចេញលុយទេ ។

ប៊ុនថន ៖ យើងចេញខ្លួនឯង?

ម្ដាយ ដារ៉េត ៖ ចាំ! អត់មានចេញឲ្យទេ ។

ប៊ុនថន ៖ ហើជាហើយបានត្រឡប់ទៅវិញអឺ?

ម្ដាយ ដារ៉េត ៖ ជាហើយត្រឡប់ទៅថ្មពួកវិញ ប៉ុនអាពកនោះនៅតែពកចេះឯង ។ ដល់ពកៗខ្ញុំនឹកឃើញថាដូចយាយថានោះថាដឹងហើយចាំមើល ណែលាបថ្នាំហើយក៏មិនៗអាពកនៅតែពកចុះឯង ។ ពកឆ្អឹងជំនីជុតចំនេះ ។

ប៊ុនថន ៖ អត់បាត់ទេអឺ?

ម្ដាយ ដារ៉េត ៖ អត់បាត់សោះ ។ ស្រាប់តែខ្ញុំនឹកឃើញដែលយាយនោះទៅប្រាប់ ក៏ទៅអញ្ជើញថាអាចារ្យនៅថ្មពួកហ្នឹងឯង ។ លោកតាអើយៗណែ ខ្ញុំថ្ងៃនេះពឹងលោកតាបន្តិចហើយ ថាពឹងស្អី ថាស្អែកនេះត្រូវសូត្រផ្ដោះគ្រោះឲ្យប្ដីខ្ញុំ ត្រូវមន្តលោកប្រាំអង្គ ។ លោកតាឯងអញ្ជើញទៅមន្តលោកឲ្យខ្ញុំបានផងទេ ថាបានមីនាង បើធ្វើបាយសីចាំតាធ្វើឲ្យយកទៅតែម្ដងចាំតាមន្តលោកតាយកទៅតែម្ដងឈ្មោះតា បាក់ៗ នោះអាចារ្យ

នោះ ។ ចោះហើយខ្ញុំពឹងលើតាណ៉ា! ខ្ញុំលាសិនហើយ ចា៎! ស្រាប់តែដល់លោកគ្រូ អើយ សូត្រស្នែកឡើងក៏សូត្រដោះគ្រោះ ប្រោសទឹកប្រោសអីទឹកមន្តទឹកអីទៅ ។ ព្រឹកឡើងដឹងទៅណាអស់ ដេកមួយហ្នឹងទៅព្រឹកឡើងលលើងធេង ។

ប៊ុនថន : ឆុតតែម្តង?

ម្តាយ ដារ៉េត : ចា៎! គ្រួសារខ្ញុំមិនដែលជឿសោះ ។ ថានេះមិនជឿ ឯងមើល ៗ ទៅណាឡើងអស់ ។ នៅបណ្តុំត្រង់នេះឡើងរីងឆ្អឹះ ។ ប្រោសទឹកប្រោសអីទៅដឹងទៅណាអស់មិនយូរទេ ។

ប៊ុនថន : ពូកែ?

ម្តាយ ដារ៉េត : ចា៎! ថាសូត្រល្វាចនេះទៅក៏ ដូចថាលោកបណ្តេញបំបរព្រាយ ៗ យកុមារអីដឹង ។

ប៊ុនថន : ប៉ុនអ៊ីប្រុសអត់ដែលជឿងទេ?

ម្តាយ ដារ៉េត : អត់ដែលជឿទេ ចា៎! ស្រាប់តែមកជឿ ៗ ដែលខ្ញុំធ្វើឲ្យ មន្តលោកមកសូត្រឲ្យហ្នឹងឯង លលាយអស់រលីង ។

ប៊ុនថន : អ៊ឹនៅថ្មពួកហ្នឹងដូចអ៊ីប្រុសមានវាយជាមួយខ្មែរក្រហមអីនៅហ្នុងទេ?

ម្តាយ ដារ៉េត : មាន ។

ប៊ុនថន : មានដែរ?

ម្តាយ ដារ៉េត : ចា៎! គាត់ដើរវាយដល់ទៅម្តុំវាយចាបនោះ ។ ទៅនេះផង ថ្មើ ៗ នេះមក ។

ប៊ុនថន : ប៉ុន្តែគាត់អត់ដែលមានគ្រោះថ្នាក់អីទេអ៊ី?

ម្តាយ ដារ៉េត : អត់ដែលមានគ្រោះថ្នាក់អីទេ ។ និយាយពីលីគ្រាប់លោកគ្រូអើយស្នាក្រិនអស់ហើយ ស្តាយគ្រាប់ស្តាយសាក់កាដូដើរ ទៅដល់ភ្នំវាយចាប ។

ប៊ុនថន : អ៊ឹមកក្រោយវិញចង់សួរពេលកំបោស្រេះអ៊ឹ ៗ ជម្លៀសទៅហ្នុង ទៅដល់ដំបូងហ្នុងអ៊ឹ ទៅនៅរបៀបម៉េចទៅដអ៊ឹនៅកំបោរស្រេះ?

ម្តាយ ដារ៉េត : នៅធ្វើកូន ធ្វើរោងនៅ ។ ធ្វើតូច ៗ ប៉ុនជង្រុកនេះឯងនៅបានប្រក់ ហើយនាំគ្នាដេធាង ត្នោតកាប់ធាងត្នោតបានដេរប្រក់ ទៅខ្ទមបេះទៅ ។ ម៉ាភូមិបេះទៅគេឲ្យនៅម៉ាកាដុប ធ្វើដូចគ្នា ធ្វើជុំវិញអាត្រង់នេះក៏របស់ខ្ញុំទៅ អាត្រង់នោះទៅក៏របស់លោកគ្រូឯងទៅ ក៏ជុំវិញទៅណា ម៉ាគ្រួសារ ៗ ។

ប៊ុនថន : កាលនោះគ្រួសារអ៊ឹប៉ុន្មាននាក់ អ៊ឹប្រុសកូន?

ម្តាយ ដារ៉េត : គ្រួសារខ្ញុំនៅជាមួយម្តាយក្មេកខ្ញុំផង ហីប្អូនស្រីក្រមុំ ៗ ខ្ញុំពីរនាក់ ហើយកូននោះប្រាំពីរ នាក់ ម្តាយម្នាក់ផង ។

ប៊ុនថន ៖ ម្តាយក្មេកអី?

ម្តាយ ដារ៉េត ៖ ចា៎! ម្តាយក្មេក។

ប៊ុនថន ៖ កាលហ្នុងអឹបងប្អូនប៉ុន្មាននាក់អី បងប្អូនអី?

ម្តាយ ដារ៉េត ៖ ខ្ញុំបែកពីម៉ែខ្ញុំ ខ្ញុំនៅតាមប្តីនោះ។ បងប្អូនច្រើនណាស់កាលនោះ។

ប៊ុនថន ៖ ប៉ុន្មានអី?

ម្តាយ ដារ៉េត ៖ ប្រាំបីនាក់។

ប៊ុនថន ៖ ប្រាំបីនាក់?

ម្តាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ ប្រុសប៉ុន្មានស្រីប៉ុន្មានអឹកាលហ្នុង?

ម្តាយ ដារ៉េត ៖ មិនបានតែរាប់សោះលោកគ្រូអើយ។ ខ្ញុំកាលនោះអូ! សម័យត្រពាំងថ្មស្លាប់មួយស្រីប្រាំនាក់។

ប៊ុនថន ៖ ស្រីប្រាំនាក់ ប្រុសបីនាក់?

ម្តាយ ដារ៉េត ៖ ចា៎! ប្រុសបួននាក់ទាំងអស់។ ចា៎!

ប៊ុនថន ៖ ប្រុសបួនស្រីប្រាំ?

ម្តាយ ដារ៉េត ៖ ចា៎! ប្រុសបួនស្រីប្រាំ។

ប៊ុនថន ៖ អឹទីប៉ុន្មាន?

ម្តាយ ដារ៉េត ៖ ខ្ញុំទីមួយ។

ប៊ុនថន ៖ កូនបងគេ?

ម្តាយ ដារ៉េត ៖ ចា៎! កូនបងគេទាំងអស់។

ប៊ុនថន ៖ ចឹងទៅនៅកំបោរស្រែះហ្នឹងមានតែប្អូនអឹពីរនាក់ ប្អូនថ្លៃអឹ?

ម្តាយ ដារ៉េត ៖ ប្អូនថ្លៃពីរនាក់កូនខ្ញុំប្រាំពីរនាក់ ហើយនឹងម៉ែក្មេកម្នាក់។

ប៊ុនថន ៖ ចោះទៅហ្នុងគ្រួសារអឹគេឲ្យធ្វើអីនៅកំបោរស្រែះ?

ម្តាយ ដារ៉េត ៖ គ្រួសារខ្ញុំគេឲ្យភ្ជួរស្រែ។

ប៊ុនថន ៖ អឹប្រុសហ្នឹង?

ម្តាយ ដារ៉េត ៖ ចា៎! កាលមុនដំបូងគេឲ្យគាត់គាស់ដីងស្អីអាគេធ្វើបារ៉ែត នៅអាដេញស្រុកយើងព្រះនេត្រព្រះ។ ណា៎! សាលាស្រុក។

ប៊ុនថន ៖ បារ៉ែតអី?

ម្ដាយ ដារ៉េត ៖ បារ៉ែតគេនោះណា៎! គេឲ្យមករំលាយ ។

ប៊ុនថន ៖ កាប៊ីនភ្លើងឬម៉េច?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ បារ៉ែតដូចម៉េចវិញអ៊ឹ?

ម្ដាយ ដារ៉េត ៖ បារ៉ែត ថាគេជីកទំនប់លោកគ្រូ ។ ទំនប់វាំងសាលាស្រុកណា៎! គេឲ្យទៅជីករំលាយ ឲ្យមកជីករំលាយចំនួនមួយអាទិត្យ ។

ប៊ុនថន ៖ ទំនប់អ៊ឹ?

ម្ដាយ ដារ៉េត ៖ ថាដូចទំនប់ចេះឯង ។ គេបិទវាំងដូចថាប៉ូលីសមន្ទីរសាលាស្រុក គេបិទវាំងខាង។ ធ្វើត្រង់សេ ។ ចឹងណា៎!

ប៊ុនថន ៖ អូ! ជីករំលាយត្រង់សេ?

ម្ដាយ ដារ៉េត ៖ ចា៎! ត្រង់សេរំលាយ គេហៅបារ៉ែត ។ ចា៎!

ប៊ុនថន ៖ ដំបូងគេឲ្យអ៊ឹប្រុសមកធ្វើនៅហ្នឹង?

ម្ដាយ ដារ៉េត ៖ ចា៎! ឲ្យមកធ្វើចំនួនប្រាំពីថ្ងៃ ដល់រួចទៅគេឲ្យគាត់ទៅភ្ជួរស្រែនៅវាលត្បូង ។

ប៊ុនថន ៖ នៅវាលណាវិញ?

ម្ដាយ ដារ៉េត ៖ នៅវាលរនាមការបៀតដូនប្រែង ខាងកើតដូនប្រែង ។

ប៊ុនថន ៖ គាត់នៅកន្ដួរកាលហ្នឹង?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ ចោះអ៊ឹស្រីនៅផ្ទះ?

ម្ដាយ ដារ៉េត ៖ ខ្ញុំនៅផ្ទះ ។ ខ្ញុំកាលហ្នុងគេមិនទាន់អនុវត្តន៍ធ្វើដេញចម្ការធ្វើអីទេលោកគ្រូ ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ ដំបូងខ្ញុំរកស៊ីតាមធម្មតាទៅ ។ អាខ្លះទៅរុត អាខ្លះទៅជញ្ជាត់ទៅ ។ ណា៎! យកមកហូប ។

ប៊ុនថន ៖ អត់ទាន់មានបែងចែកអីទេ?

ម្ដាយ ដារ៉េត ៖ ចា៎! អត់ទាន់មានបែងចែកទេ ។ ស្រាប់តែដល់ខ្ញុំគេជម្លៀសពីស្រែះមក មកនៅប៉ោយព្រីង ប៉ោយសំរោងត្រង់ណោះបានគេបែងចែក ។ គេបែងចែកឲ្យខ្ញុំត្បាញសារុង ត្បាញកន្សែង ។ ត្បាញបានប្រហែលជាចំនួន អ្ហឹ! បីខែបួនខែ ដកខ្ញុំឲ្យទៅដេរ។ ខោអាវឲ្យប្រជាជនដែលគាត់ចល័តគាត់ទៅណា ។

ប៊ុនថន :　　ត្បាញកាលហ្នុងត្បាញជាមួយពីណាអ៊ឹ?

ម្តាយ ដារ៉េត : ត្បាញ!

ប៊ុនថន :　　មានកងត្បាញគេ?

ម្តាយ ដារ៉េត : អត់មានកងទេ ៗ　នៅជាមួយចាស់ៗក្នុងភូមិ　ដែលខ្ញុំកូនខ្ចីចឹងទៅគេឲ្យនៅតាមភូមិ ឲ្យត្បាញជិតៗក្នុងភូមិ ៗ បន្ទាប់ពីត្បាញទៅបានប្រហែលពីរបីខែ ដកខ្ញុំចេញទៅឲ្យទៅដេរៗក្នុងភូមិដែរ ៗ ចា៎!

ប៊ុនថន :　　ដេរអីគេវិញអ៊ឹ?

ម្តាយ ដារ៉េត : ដេរអាវដេរខោ ៗ ឲ្យដេរចំនួនបួនប្រាំខែដកខ្ញុំឲ្យទៅធ្វើជីវភាព ៗ

ប៊ុនថន :　　ដេរខោអាវអីវិញអ៊ឹយើងធម្មតា?

ម្តាយ ដារ៉េត : សំពត់ស ៗ

ប៊ុនថន :　　សំពត់ស?

ម្តាយ ដារ៉េត : ចា៎! ក្រណាត់ស ៗ

ប៊ុនថន :　　ដេរយកទៅណាទៅអ៊ឹ?

ម្តាយ ដារ៉េត : ដេរឲ្យប្រជាជនយើងហ្នឹងឯងដែលគ្នាទៅចល័តទៅអីទៅវាពុកវារហែកទៅបានគេបើកអាវនោះឲ្យ ៗ

ប៊ុនថន :　　បាទឲ្យដេរ?

ម្តាយ ដារ៉េត : ដេរក្រណាត់សនោះហ្នឹងឯង　ដេររួចហើយក៏ជ្រលក់ណែអាដេញដើមត្រស់ស្ងោរជាតិជ័រ ៗ ដើមត្រស់ជាតិអីឲ្យតែមានខ្មៅមានក្រហម ស្ងោររួចទៅយកទៅជាន់នឹងផុកជាន់ផុកឲ្យខ្មៅ ហើយវាខ្មៅមិនមែនខ្មៅសុទ្ធដូចយើងចេះ ៗ ណា៎! វាប្រេះៗ ក្រហមព្រឿងៗ ជ្រលក់សំបកឈើ ៗ

ប៊ុនថន :　　ត្រស់ដូចម៉េចវិញដើមត្រស់?

ម្តាយ ដារ៉េត : ដើមត្រស់វាដើមតូចៗ ប៉ុនវាជ័រ ៗ

ប៊ុនថន :　　ដើមម៉ាក់ក្លឿទេអ៊ឹ?

ម្តាយ ដារ៉េត : អត់ទេដើមត្រស់ ៗ　អត់មានម៉ាក់ក្លឿទេនៅនេះ　បើមានម៉ាក់ក្លឿជ្រលក់ម៉ាក់ក្លឿ ៗ ដើមត្រស់សំបកស្រម៉ សំបកត្រកួនទឹកណោះ ចេះនាំគ្នាយកមកស្ងោរជ្រលក់ទៅ ៗ

ប៊ុនថន :　　ស្ងោរ?

ម្ដាយ ដារ៉េត ៖ ចា៎! ស្វាវបានចេញជ័រទៅយើងដាក់អាវនោះស្វាវទៅជាមួយឲ្យវាចេញជ័រទៅវាប្រ
លាក់ទៅវាខ្មៅ ក្រហមៗ ។

ប៊ុនថន ៖ ហើចេញនៅដេរប្រាំមួយខែហើយអីទៅណាទៀត?

ម្ដាយ ដារ៉េត ៖ គេឲ្យទៅធ្វើជីវភាពបានប្រហែលជាចំនួនប្រាំខែដកខ្ញុំ ។

ប៊ុនថន ៖ ជីវភាពនៅណាអី?

ម្ដាយ ដារ៉េត ៖ ជីវភាពនៅហ្នឹងភូមិហ្នឹងឯង ។

ប៊ុនថន ៖ ជីវភាពនៅភូមិ?

ម្ដាយ ដារ៉េត ៖ នៅហ្នឹងភូមិ ។

ប៊ុនថន ៖ ធ្វើជីវភាពធ្វើអីវិញអី?

ម្ដាយ ដារ៉េត ៖ ដាំបាយ ។

ប៊ុនថន ៖ ជីវភាពដាំបាយ?

ម្ដាយ ដារ៉េត ៖ ដាំបាយ ចា៎! ធ្វើម្ហូបធ្វើអី ពួកចល័តគេអ្នកហូប អ្នកភូមិអីទៅបើក ៗ ណា៎!

ប៊ុនថន ៖ កាលហ្នុងនៅណាអីប៉ោយ?

ម្ដាយ ដារ៉េត ៖ នៅប៉ោយសំរោង ។

ប៊ុនថន ៖ ប៉ោយសំរោង?

ម្ដាយ ដារ៉េត ៖ ចា៎! ដល់គេយកឆ្នាំ៧៧ហើយ គេយកគ្រួសារខ្ញុំទៅវាយចោលក៏គេដកខ្ញុំចេញមក ។

ប៊ុនថន ៖ កាលហ្នុងបានគេវាយយកអីប្រុសទៅអីកាលហ្នុង?

ម្ដាយ ដារ៉េត ៖ ដឹងដែរប្រវត្តិទាហាន ។

ប៊ុនថន ៖ ម៉េចបានគេដឹងអីកាលហ្នុង?

ម្ដាយ ដារ៉េត ៖ គេដឹងចោះភូមិហ្នឹងឯង ៗ អ្នកភូមិនេះគេដឹង គេថាគេចោទដល់ស័ក្តិបីជង ។

ប៊ុនថន ៖ ស័ក្តិបី! ចោះការពិតគ្រួសារអី?

ម្ដាយ ដារ៉េត ៖ អត់មាន ។

ប៊ុនថន ៖ អត់មានស័ក្តិទេ?

ម្ដាយ ដារ៉េត ៖ កាប៊ូរ៉ាល់ សែបណោះ ។

ប៊ុនថន ៖ កាប៊ូរ៉ាល់?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ កាប៊ូរ៉ាល់អត់ទាន់មានស័ក្តិទេអី?

ម្ដាយ ដារ៉េត ៖ អត់ទាន់មានទេ ។ ទាល់ស័ក្តិមួយបានមានស័ក្តិ ។

ប៊ុនថន ៖ កាលនោះអ៊ីប្រុសគាត់នៅណាគេទៅចាប់គាត់?

ម្ដាយ ដារ៉េត ៖ នៅហ្នឹងប៉ោយសំរោងនោះឯង នៅហ្នឹងផ្ទះជាមួយគ្នា ។ ពីថ្ងៃហ្នឹងគាត់ទៅ គេឲ្យទៅធ្វើអីទេទៅរនាម ។ ចាំ! ទៅដល់ល្ងាចឡើងមក ហូបតែបបររួច ។ ខ្ញុំថ្ងៃនោះក៏ចេះតែស្រម័យដែរថា ល្ពុងអញផ្លែតាពីរ ងើយមើលល្ពុងសារៀម ផ្លែតែពីរអញបេះបបរឲ្យគ្រួសារអញហូបមួយដឹង ក្រែងគេទៅណាឆ្ងាយអីល្ពុងនេះទំចេះៗឆ្ងល់តែចេះឯង ហីកូនក៏ ។ ហីគាត់មកក៏បានពោតដែលក្អែកហែកនោះ គាត់កាច់យកមក ។ បានបួនប្រាំមកក៏យកមកច្រូត ចិតពោតហ្នឹងចិតលាយនឹងល្ពុងហ្នឹងឯង ។ បបរនោះមិនមានគ្រាប់អង្ករទេលោកគ្រូ បបរដាក់តែអំបិលឆ្អិនក៏ដួសចែកកូនម្នាក់មួយវែកៗទៅ ។ ហូបតែរួចមិនទាន់អន្តុយបានប្រហែលជាបានសាមសិបនាទីផងគេមកហៅ ព្រលប់ហើយគេមកហៅ ។

ប៊ុនថន ៖ ម៉ោងប៉ុន្មាន?

ម្ដាយ ដារ៉េត ៖ ប្រាំពីរអីដឹង ។ ប្រាំពីល្ងាចមកហៅ បងអើយបងៗចុះមកណេះ ។ ខ្ញុំក៏កូនៗងឹំនោះវាចុះអាចម៍រាកអើយរាក ខ្ញុំក៏គ្រាកូនចុះមកតាម ។ ដេញគ្រួសារខ្ញុំចុះទៅក៏ខ្ញុំគ្រាកូនចុះមកតាមរួចគាត់ក៏ឡើងទៅវិញ ឡើងទៅវិញគេយកអាវពាក់ ។ អត់មានប្រាប់ខ្ញុំណែឯងឆាប់ទៅឆាប់មកណាខ្ញុំកាត់សក់ឲ្យកុំទៅយូរវើយសក់វែងណាស់ ។ ដល់ក៏បាត់ជ្រាប់ទៅលោកគ្រូ ហើយស្រាប់តែផ្ទះអ្នកជិតខាងនិយាយពី ពួកនេះគេទៅចាប់ ។ លោកគ្រូអើយក៏រត់ដូចគោហ្វូង ។

ប៊ុនថន ៖ ម៉េចវិញអ៊ី?

ម្ដាយ ដារ៉េត ៖ វារត់ ។ ចាប់បានក៏វាយគ្នា វាវាយឡើងនុលពុស៊ុលលោកគ្រូអើយ ។ ឆ្ងាយពីផ្ទះនេះឯងពុ ប្រហែលជាផ្ទះខ្ញុំនោះ ពុស្រុលហីក៏ខ្ញុំអត់មានចាប់ភ្នែកថាគេយកប្ដីឯងទៅវាយចោលក៏អត់ អត់មានចាប់ភ្នែកទេ ។ អត់ដឹងគាត់គិតទេលោកគ្រូ ស្រាប់តែស្អែកឡើងក្នុងខ្លួនខ្ញុំ ថ្ងៃរះដុលក្នុងខ្លួនខ្ញុំបុកភឹប ។ អីយ៉ាមិនកើតទេ យ៉ាងណាចេះៗ ថេង អើយឪពុកអ្ហែងយ៉ាងណាចេះបែកគ្នាហើយកូន ។ ខ្ញុំគិតធ្វើម៉េចបោះដឹងធ្វើម៉េចៗ បើយើងនិយាយទៅយើងថាទៅខ្លាចងាប់ទាំងអស់គ្នា ។ ឪពុកយើងមុខតែសូន្យហើយ ថាចឹងកូនអើយ ។ ខ្ញុំក៏យំអន្តុយយំជាមួយកូន ដល់ហើយគេយកពុកយើងទៅសម្លាប់ចោលហើយកូនអើយប៉ុណ្ណោះហើយ ។

ប៊ុនថន ៖ កាលនោះអ៊ីកូនទីប៉ុន្មានហើយអ៊ី?

ម្ដាយ ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ អ៊ីមានកូនទីប៉ុន្មានហើយអ៊ី?

ម្ដាយ ដារ៉េត ៖ ខ្ញុំកូនទី៧ហើយ ទី៧ទី៨ហើយកាលហ្នឹង ។ បើវាស្លាប់ទី៧មួយទី៨នោះមួយ ។

ប៊ុនថន ៖ ចុះអ៊ីអត់ទាន់ដឹងថាចាប់ទេអាពេលក្បាលល្ងាចនោះ?

ម្ដាយ ដារ៉េត ៖ ទេគេចាប់អត់ឲ្យឃើញ គ្រាន់គេហៅពីផ្ទះទៅ ខ្ញុំស្មានថាគេហៅទៅណាធម្មតាណាលោកគ្រូ ។ ស្រាប់តែដល់ស្អែកឡើងក៏ខ្ញុំស៊ើបសួរគេគេថា អ្នកជិតខាងគេឃើញគេលបមើលណាថា អ្ហ៎! ប្ដីឯងគេចាប់ចងស្លាបសេក ក៏ខ្ញុំក៏យំអើយយំតែយំតែខ្ទប់ចេះអត់ហ៊ានឲ្យគេឮទេ ។ ខ្ញុំក៏យំដឹងធ្វើម៉េចទេ ក៏ស្រាប់តែអាអ្នកដែលហៅទៅៗសួរ បានពីរថ្ងៃអាអ្នកហៅទៅវាមកយកខ្សែមកយក មកយកគោ វាមកយកអាត្រមោងវាយគោនោះ វាភាវរកទាំងអស់ហើយ ។ សួរថា អានោះអ្នកភ្នំពេញទេ ប៉ុន្តែវាអឺជិតស្និទ្ធនឹងខ្ញុំណាស់ រាប់អានខ្ញុំដូចជាបងវាបង្កើតចេះឯង ។ ថាអាអូនអើយយកណែ បងអាអូនឯងទៅណាយប់មិញ ។ បងអើយបងៗ ប៉ុនមុននឹងបងខ្ញុំស្លាប់ បងខ្ញុំមិនមានវេទនាដូចគេទេបងអើយ ។ គេវាយណាបង និយាយពីចងខ្សែបាន អាខ្លះដើរឃើតក៏គេធាក់ដួសក៏ដួលទៅ ប្រទាញប្រទងគ្នា ចំណែកបងខ្ញុំៗដើរតែគៀង ។ វាគេឲ្យធ្វើឈ្ងបភូមិ ។ មុននឹងគាត់ស្លាប់ម៉ាដងបងស្លាប់តែម្ដង អត់មានវេទនាដូចគេទេបងខ្ញុំ ។ ខ្ញុំដើរតែគៀងអត់មានឲ្យនរណាដើរបៀតទេ ដុតពីនោះពួកផ្សេងៗដើរបណ្ដើរវាយផង ធាក់ផង ចំពោះបងខ្ញុំមួយល្អណាស់ មុននឹងគាត់ស្លាប់តែមួយដងស្លាប់ ។ ទៅខ្ញុំក៏មិនដឹងធ្វើម៉េចដែរ ខ្ញុំស្រែកយំហ៊ូ ។ ប៉ុនខ្ញុំថា កូនឯងហៅបងយកទៅសម្លាប់ចោលចេះបង ខ្ញុំមិនបាននេះទេបងខ្ញុំណែគេប្រើខ្ញុំមកយកប្រគល់ឲ្យគេ ។ ខ្ញុំយកទៅទុកអាកន្លែងប្រធានដូចថាយើងចៅហ្វាយស្រុកណាឈ្មោះ គាក្រុកៗ យកទៅទុកកន្លែងនោះឯង ដឹងគេយកធ្វើម៉េចទៀតក៏មិនដឹងទេ ។

ប៊ុនថន ៖ ទុកនៅកន្លែងណាវិញអ៊ី?

ម្ដាយ ដារ៉េត ៖ កន្លែងត្រង់ណោះ អាកន្លែងចូលភ្នំលោកគ្រូ ។ ផ្ទះគេនៅត្រង់នោះឯង ផ្ទះប្រធានខ្មែរក្រហម ផ្លូវគេឡើងភ្នំ ផ្ទះគេនៅត្រង់នោះឯង ។ ខ្ញុំយកទៅប្រគល់ឲ្យគេត្រង់នោះឯង បងមិនដឹងគេធ្វើយ៉ាងម៉េចទេ ។

ប៊ុនថន ៖ គេហៅអីវិញកន្លែងហ្នឹង?

ម្ដាយ ដារ៉េត ៖ កន្លែងត្រង់នោះគេហៅប៉ោយក្លឿង កន្លែងគោកតាយូរ ។ គេហៅគោកតាយូរជាប់ប៉ោយក្លឿងនេះឯង ។

ប៊ុនថន ៖ គោកតាយូរ?

ម្ដាយ ដារ៉េត ៖ ចាំ!

ដារ៉េត ៖ កន្លែងដកពរ ។

ម្ដាយ ដារ៉េត ៖ អ្ហឺ! ដកពរ កន្លែងនោះហៅដកពរកន្លែង សហករណ៍មួយ ។

ប៊ុនថន ៖ សហករណ៍មួយ?

ម្ដាយ ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ ចឹងតាក្រុកនៅហ្នឹង?

ម្ដាយ ដារ៉េត ៖ តាក្រុកនៅហ្នឹងឯង ។

ប៊ុនថន ៖ នៅជិតផ្ទះគាត់ឬនៅណា?

ម្ដាយ ដារ៉េត ៖ គេឲ្យយកទៅឲ្យគាត់មិនដឹងយកទៅណា ។ កូនចៅគាត់ពួកនារីស្អីគេ នារីនិរតី ។

ប្រុញ ៖ អឺអ្នកមកហៅប្ដីអឺឈ្មោះស្អីគេ?

ម្ដាយ ដារ៉េត ៖ ឈ្មោះ ប៉ោ ឡេង ។ ប៉ោ ឡេងមួយ ម៉េង មួយ ។

ប៊ុនថន ៖ ម៉េង ហ្នឹងអ្នកភ្នំពេញដែរ?

ម្ដាយ ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ ឈ្លបដែរ?

ម្ដាយ ដារ៉េត ៖ ចាំ! ឈ្លប ។ ប៉ោ ឡេង ។

ប្រុញ ៖ មួយទៀតៗ?

ម្ដាយ ដារ៉េត ៖ ឈ្មោះស្អីអេងទេ ម៉េង ។ យល់តែណេងៗ នោះក៏អ្នកមកពីភ្នំពេញដែរ ។

ប៊ុនថន ៖ ចឹងគាត់និយាយប្រាប់គាត់ គាត់និយាយប្រាប់អឺនិយាយថា ប៉ោឡេង ហ្នឹងពេលអឺសួរ?

ម្ដាយ ដារ៉េត ៖ អត់ទេ នៅភូមិជុំគ្នា ។ ដែលគេមកយកហ្នឹងខ្ញុំឃើញណា ខ្ញុំបណ្ដើរគ្នាចេះទៅក៏គេហៅចេះទៅដឹងគេបណ្ដើរដល់ត្រង់ណាគេចាប់ ខ្ញុំក៏បកមកវិញមក ។

ប៊ុនថន ៖ ប៉ោឡេងហ្នឹងគាត់ចង់តែម្ដង?

ម្ដាយ ដារ៉េត ៖ មិនដឹងអ្នកណាចងទេ ។ ខ្ញុំអ្នកណាចងក៏ខ្ញុំមិនដឹង ប៉ុនអ្នកបងប្អូននៅក្នុងភូមិនេះគេលបមើលឃើញ ។

ប៊ុនថន ៖ លបមើលឃើញ?

ម្ដាយ ដារ៉េត ៖ មើលឃើញគេឱ្យបប្រាប់ខ្ញុំ តែពិតមិនពិតខ្ញុំមិនដឹងទេ។ ប៉ុន្តែស្លាប់ហើយចេះតែមាន ហើយចង ហើយគេអាដេញ ប៉ោឡេង នោះវានិយាយប្រាប់ខ្ញុំថា បងខ្ញុំមុនហ្នឹងស្លាប់អស់ចិត្ត មាននរណាធាក់ មាននរណាច្រំ មាននរណាវាយបងខ្ញុំ ខ្ញុំបណ្ដើរជូនទៅដល់លោក តាក្រុក ហ្នឹង ដល់ប្រធានគេ។

ប៊ុនថន ៖ ចោះគាត់និយាយប្រាប់អ៊ឹអត់ខ្លាចអ៊ីខឹងទេ?

ម្ដាយ ដារ៉េត ៖ ទេដែលខ្ញុំលួចសួរពេកហើយ ជិតស្និទ្ធិហ្នឹងខ្ញុំស្រឡាញ់ខ្ញុំដូចបងបង្កើត។ អត់ខ្លាចខឹងទេ ព្រោះខ្ញុំមិនបានខឹងទេអូនអើយ អូននិយាយប្រាប់បងឲ្យអស់មក។ ខ្ញុំមិនបានថានេះទេ ធ្វើម៉េចណែសម័យគេត្រូវចេះទៅហើយ អូនឯងប្រាប់បងមកក៏ប្រាប់។

ប៊ុនថន ៖ ហើយអ៊ឹមានប្រាប់ថា មានសួរថាស្លាប់នៅណាអីដេះអ៊ឹ?

ម្ដាយ ដារ៉េត ៖ សួរតើ។ គេយកទៅទុកដាក់កន្លែងណាអូន ថាខ្ញុំមិនដឹងទេបងអើយខ្ញុំយកទៅប្រគល់ឲ្យតែតាក្រុកគេឲ្យមកវិញ។

ប៊ុនថន ៖ ផ្ទះតាក្រុកនៅភូមិអីសព្វថ្ងៃ?

ម្ដាយ ដារ៉េត ៖ នៅភូមិដកពរ នៅផ្លូវចូលមកភ្នំហ្នឹងណ៎ា! គេធ្វើមុខទាហានខាងកើតភ្នំ។

ប៊ុនថន ៖ គាត់នៅហ្នុងតែម្ដងភូមិដកពរ?

ម្ដាយ ដារ៉េត ៖ ចា៎! មិនមែននៅភូមិកំណើតនោះទេ។ គេជម្លៀស ចា៎! ស្នាក់នៅ ចា៎! គេជម្លៀសមកពីស្រុកអីកើតដឹងស្រុកអីទេ។

ដារ៉េត ៖ ហៅថាពជ្រចោះអីទេ។

ប៊ុនថន ៖ គាត់នៅពជ្រ តាក្រុក?

ម្ដាយ ដារ៉េត ៖ នៅពជ្រអីទេ ខ្ញុំមិនដែលដឹងព្រោះតែគេនិយាយ។ តាក្រុក ហើយប្រធានធំ ប្រធានស្រុក។

ប៊ុនថន ៖ ចោះអ៊ឹដូចព្រោះគាត់និយាយចឹងហើយអ៊ឹអារម្មណ៍ម៉េចទៅពេលហ្នឹង?

ម្ដាយ ដារ៉េត ៖ ខ្ញុំយំយកៗខ្ញុំនិយាយមិនរួច។ មើលតែសៀបតែកូន អន្ទុយយំសៀបក្បាលកូនៗ។

ប៊ុនថន ៖ ហឺ ប៉ោឡេង គាត់ថាម៉េចឃើញអ៊ឹយំ?

ម្ដាយ ដារ៉េត ៖ ដើរចេញទៅ។ ផ្ទះនៅដោយខ្លួន ទៅផ្ទះគេបាត់ទៅ។ យកតែខ្សែយកតែគោដេញគោដេញអីទៅ យករទេះយកអីទៅ។

ប្រុញ ៖ ប៉ោឡេង ហ្នឹងមកយកអីវ៉ាន់នៅផ្ទះអ៊ឹ?

ម្ដាយ ដារ៉េត ៖ ចា៎! យកគោគេដាក់ គេប្រគល់គោ ៗ ត្រង់ណាដែលគ្រួសារខ្ញុំ ដែលគាត់កាន់គាត់ប្រើ ៗ ណា៎! ឲ្យប្រគល់ទៅឲ្យ ប៉ោឡេង ហើយមិនដឹង ប៉ោ ឡេង យកទៅឲ្យអ្នកណាទៀតខ្ញុំមិនដឹងទេ ខ្ញុំយំទៅ ៗ លោកគ្រូអើយបានថាស្ងប់យប់បានមួយថ្ងៃពីរថ្ងៃសោះអស់ហើយ ក៏ខ្ញុំឈប់ ៗ ធ្លាក់បានប្រាំពីរថ្ងៃ ដល់គេចែករបបបាយមកម្នាក់មួយវែក នាំកូនហូបនោះហើយកន្ទេលបៀតពោងបាយគេ ៗ អាប្រុសកូនខ្ញុំនោះវានៅតូចនោះ ម៉ែអើយអីណាបាយពុក ខ្ញុំឆ្អែតខ្ញុំស្រែកយំចំហ ខ្ញុំឈប់បិទហើយ ខ្ញុំឈប់ខ្ទប់ហើយងាប់ខ្ញុំក៏ងាប់ទៅចោះ ឆ្អែតណាស់ ៗ ពុកូនថាអីចោះក៏ខ្ញុំយំយកៗឡើងងើងៗពេញតែនេះនោះឯង មានអ្នកគេមកនាងអើយឈប់យំទៅ ខ្លាចគេសម្លាប់នាងឯងងាប់ចោលកូន ៗ ងាប់ត្រង់នេះងាប់ទាំងកូនទាំងចៅចោះ ខ្ញុំមិនចង់រស់ទេអត់ពីប្ដីខ្ញុំហើយ ៗ

ប៊ុនថន ៖ ប៉ុន្តែគេអត់ថាអីដែរពេលអ៊ីយំអីចឹង?

ម្ដាយ ដារ៉េត ៖ អត់ទេគេអត់ថាអីទេ ប្រធានៗទៅអស់ហើយនោះ ចេញទៅណាអស់ ៗ គេចែករបបក៏នាំកូនទៅហូបៗ អាមួយវាឆ្លើយថា ម៉ែអើយទុកបបរឲ្យពុកហើយ ៗ ខ្ញុំក្រៃយំខ្លាំងៗស្រែកយំមែនទែន ៗ

ប៊ុនថន ៖ ឈ្មោះអីវិញកូនប្រុសអ៊ី?

ម្ដាយ ដារ៉េត ៖ នេះឈ្មោះ អាយឿន ៗ វានៅតូចប៉ុណ្ណេះ ៗ

ប៊ុនថន ៖ ប៉ុនចេះនិយាយ?

ម្ដាយ ដារ៉េត ៖ ចេះនិយាយៗ ចេះសួរ ៗ ប្អូនពីរនោះណា ប្អូនបី ៗ ចេះនិយាយចេះដើរ ៗ

ប៊ុនថន ៖ ចុះអឹចង់សួរបន្តិចឈ្មោះ ប៉ោ លី នោះរាប់អានគ្រួសារអ៊ីតាំងពីដំបូង?

ម្ដាយ ដារ៉េត ៖ អត់ទេ ៗ គាត់ទេជម្លៀសគាត់មកក៏គាត់ គ្រួសារខ្ញុំស្អូតនោះ គាត់ដើរតាមគ្រួសារខ្ញុំនេះឯង ៗ ស្រណោះបងៗ ៗ អ្នកណាក៏ដោយឲ្យតែអ្នកជម្លៀសមកពីនោះស្រឡាញ់គាត់ទាំងអស់ មិនថាស្រីមិនថាប្រុសទេ ៗ បើកូនចៅគេឈឺចេះក៏ គ្នាអត់ប្ដី ណា៎! កូនចៅឈឺក៏ គ្នាអត់ប្ដី ណា៎! កូនចៅឈឺចឹងក៏ ពូអើយពូជួយខ្ញុំ ក៏ជួយបីជួយអីទៅពេទ្យនៅឯវត្តនោះ ណា៎! លោកគ្រូ ឆ្ងាយណាស់ ណា៎! ជាងមួយគីឡូ ៗ

ប៊ុនថន ៖ វត្តព្រះនេត្រព្រះហ្នឹងអ៊ី?

ម្ដាយ ដារ៉េត ៖ ចា៎! ពេទ្យនៅនោះឯងក៏នាំគេ ជួយគេបីគេទៅហើយ ។ ជួយគ្នាវាអត់ពឹងតែគាត់នោះ ឯង តែគ្នាទាំងអស់មានប្រុសមានប្ដីប្រពន្ធៗ អ្នកភូមិគេនៅទាំងអស់ មានណាសួរ ត្រូវដូចគាត់រលីង ។ គេស្រលាញ់គាត់ណាស់ គាត់ស្លូត ពឹងគាត់ទៅណាក៏បានៗ ។

ប៊ុនថន ៖ ចឹង ប៉ោ លី គាត់មកហ្នឹង ប្រុសក៏ស្រី ប៉ោ លី ហ្នឹង?

ម្ដាយ ដារ៉េត ៖ ប្រុស ។

ប៊ុនថន ៖ មានគ្រួសារដេះកាលហ្នុង?

ម្ដាយ ដារ៉េត ៖ អត់ ។ នៅកំលោះ ។

ប៊ុនថន ៖ ចឹងមកតែម្នាក់ឯងទេ ក៏មានបងឪពុកម្ដាយមកទៀត?

ម្ដាយ ដារ៉េត ៖ មិនដែលសួរហ៊ានដើរ មិនដឹងគេមកជាមួយម្ដាយក្រុមគ្រួសារគេយ៉ាងណាក៏ខ្ញុំអត់ដឹង ទេ ។

ដារ៉េត ៖ មានគ្រួសារហ្នឹងឯងនៅហ្នឹងផ្ទះតាហា ។

ម្ដាយ ដារ៉េត ៖ ខ្ញុំមិនដឹងទេ ។

ប៊ុនថន ៖ មានគ្រួសារដែរ?

ដារ៉េត ៖ រាងចិនឪពុកគាត់ចិន ហើយគាត់មានមួយក្រុមគ្រួសារគាត់ ហើយគាត់មានប្រពន្ធកូន អត់ដឹងទេ ។

ម្ដាយ ដារ៉េត ៖ អត់ទាន់មានទេ ។

ប៊ុនថន ៖ ប៉ុនមានឪពុកម្ដាយមកដែរ ។ ចោះនិយាយថាគាត់អាយុប៉ុន្មាន ប៉ោ លី ហ្នឹង?

ម្ដាយ ដារ៉េត ៖ មិនដឹងដែរលោកគ្រូ ខ្ញុំមិនដែលបានសួរបានអីទេ ។

ប៊ុនថន ៖ ប៉ុន្តែក្មេងទេ?

ម្ដាយ ដារ៉េត ៖ កាលនោះបានថាយ៉ាងច្រើនណាស់ ក្មេង ខ្ទង់២០ហ្នឹងឯង ។ ចា៎! ២១-២២ អីហ្នឹងឯង ។

ប៊ុនថន ៖ ប៉ុន្តែដូចមកដំបូងអីចឹងគាត់រាប់អានជាមួយគ្រួសារអីអីចឹង?

ម្ដាយ ដារ៉េត ៖ ចា៎! គាត់ស្គាល់ៗចឹងក៏ស្គាល់គាត់ទៅ ។ គ្រួសារខ្ញុំគាត់ទៅឃ្វាលគោ គាត់ទៅភ្ជួរទៅ អីក៏គេឲ្យពួកគាត់ទៅជាមួយ អ្ហា៎! គាត់រាប់អានគាត់ស្លូតនោះ ។

ប៊ុនថន ៖ អ្នកនៅណាវិញ ប៉ោ លី ហ្នឹង នៅភ្នំពេញអី?

ម្ដាយ ដារ៉េត ៖ នៅភ្នំពេញ ។ ដឹងនៅណាទេលោកគ្រូអើយដែលបែកបាក់ដែលយួនចូលហ្នឹង ក៏ខ្លះក៏ ទៅសាប់អាកន្លែងឈ្នួរអស់ច្រើនណាស់ ។ មិនដឹងជាសាប់មិនដឹងជារស់ ។

ប៊ុនថន ៖ ចោះម៉េចដូចថាអ្នកថ្មីគេជ្រើសរើសធ្វើដូចថា ធ្វើខាងឈ្លបធ្វើខាងអីដែរអ៊ឹ?

ម្ដាយ ដារ៉េត ៖ មិនដឹងដែរណា ។ គេឲ្យធ្វើខាងឈ្លបខាងអី ហីចោះប្រធាន ។

ដារ៉េត ៖ ឲ្យតែអ្នកជម្លៀសនោះលោកគ្រូ ។

ម្ដាយ ដារ៉េត ៖ ឲ្យតែអ្នកជម្លៀស ។

ដារ៉េត ៖ ឲ្យអ្នកជម្លៀសមានមុខដូនកាលគេប្រុងយកគាត់ទៅវ៉ាយចោល ។ ដល់ជម្លៀសមក គេឲ្យធ្វើប្រធានវ៉ាយសម្លាប់ សម្រាប់សម្លាប់អ្នកស្រុកយើងនៅអីណេះ ។ ហីមុខគាត់ គាត់មក គាត់ថាគេយកគាត់ទៅវ៉ាយចោលដែរហ្នឹង ភ័យដែរ ។ ដល់ពេលស្រាប់គាត់ មកជាចៃដន្យល្អសំណាងល្អរបស់គាត់ ប្រធានដឹកនាំពួកភូមិយើងទៅបើថាត្រូវការ ចាប់អ្នកណាយកអ្នកណាទៅវ៉ាយចោលបញ្ជាគាត់ បើសិនជាទំទាស់គេសម្លាប់គាត់ ។

ប៊ុនថន ៖ ចោះអ្នកមីងមានអ្នកផ្សេងអីទៀតទេដូចថាក្រៅពី ប៉ោ លី ហ្នឹងដូចថាឲ្យធ្វើឈ្លបធ្វើ អីអ្នកជម្លៀសមកថ្មី?

ម្ដាយ ដារ៉េត ៖ មាន ប៉ុន្តែខ្ញុំមិនសូវដែលស្គាល់គេ ។

ប៊ុនថន ៖ មានទៀត?

ម្ដាយ ដារ៉េត ៖ ចា៎! មាននេះឯង ប៉ុន្តែខ្ញុំមិនសូវដែលស្គាល់គេ ។ ស្គាល់ អា ប៉ោ ឡេង ហ្នឹងហើយ ច្បាស់ដែលវ៉ា ។

ដារ៉េត ៖ មានតែប្រធានភូមិដែលមកឆ្ងាយៗ ។

ប៊ុនថន ៖ ចោះក្រោយមកដូចថា ប៉ោ ឡេង នៅដូចថានៅរាប់អានជាមួយអ៊ំទេ?

ម្ដាយ ដារ៉េត ៖ អត់គេជម្លៀសទៅអស់ហើយ ក៏ទៅអស់រហូតឡើយទៅឡើយ ។

ប៊ុនថន ៖ ជម្លៀសទៅណាវិញ ប៉ោ ឡេង ក្រោយមក?

ម្ដាយ ដារ៉េត ៖ អ្ហឺ! ជម្លៀសអីដែលអាពតចូលគេរត់ទៅស្រុកប្រសេកប្រសាចលោកគ្រូ ។ មិនដឹង ជារស់មិនដឹងជាស្លាប់ ស្រាប់បាត់រហូត ។

ប៊ុនថន ៖ ឆ្នាំប៉ុន្មានអ៊ីកាលគេចាប់អ៊ីប្រុសឆ្នាំ៧៧មានចាំខែទេអ៊ី?

ម្ដាយ ដារ៉េត ៖ ចា៎! ឆ្នាំ៧៧ ចុងខែ ។ ខែពិសាខហើយ ។

ប៊ុនថន ៖ ខែពិសាខ ពាក់កណ្ដាល?

ម្ដាយ ដារ៉េត ៖ ពីខែជេស្ឋ អាសាឍ នេះឯង ។

ប៊ុនថន ៖ ខែជេស្ឋ អាសាឍ?

ម្ដាយ ដារ៉េត ៖ ខែ៧ ខែ៨ ។ ខែ៨ ហ្នឹងហើយ ។

ប៊ុនថន ៖ ខែប្រាំបី ៧៧ គេយកទៅ?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ ចោះអ៊ីយកទៅហើយអ៊ីថាគេដកទៅណាទៀតអ៊ីកាលហ្នុង?

ម្ដាយ ដារ៉េត ៖ យកគាត់ទៅហើយ!

ប៊ុនថន ៖ គេបញ្ជូនអ៊ីទៅណាទៀត?

ម្ដាយ ដារ៉េត ៖ អត់មានគេបញ្ជូនទេដុតពីនោះ ។ មានគេបញ្ជូនខ្លះៗ តែខ្ញុំមិនបានបញ្ជូនទេ?

ប៊ុនថន ៖ អ៊ីនៅណាទៅអ៊ី?

ម្ដាយ ដារ៉េត ៖ ខ្ញុំនៅតែហ្នឹងនៅក្នុងភូមិប៉ោយសំរោងហ្នឹងឯង ។ ខ្ញុំដេកតែបន់ព្រះសំពះទេវតា ។ លោកគ្រូអើយដែលហ៊ានបានដេកស្រួលនាំកូន បើថាផ្ទះចេះ ចង្រ្កានចេះក៏នាំកូនមករៀននៅចង្រ្កាន មិនដែលហ៊ានដេកនៅតួផ្ទះទេ ។ ហើបើកូនហ៊ានតែនិយាយ យំបន្តិចក៏នាំខ្ទប់មាត់ ។ មិនដែលបានដេកទេលោកគ្រូអើយ មិនដែលបានឆ្ងេចទេអីណាអត់ពីប្ដីទៅផង អីណាស្រុកគេរកតែវាយចោលចេះ ។ លោកគ្រូអើយដូចទឹកលើស្លឹកឈូកអណ្តែតអណ្ដូងណាស់ ។

ប៊ុនថន ៖ អ៊ី ប៉ុន្តែគេឲ្យអ៊ីធ្វើការអីដែរអ៊ីនៅភូមិហ្នឹងកាលហ្នឹង?

ម្ដាយ ដារ៉េត ៖ ដែលខ្ញុំកូនខ្ញុំអីចេះទៅគេឲ្យធ្វើការ អត់ពីប្ដីខ្ញុំទៅគេដកខ្ញុំចេញពីកន្លែងជីវភាពនេះទៅគេឲ្យខ្ញុំជីវកម្ម អូសមង អូសកំពឹស អូសអី ។

ប៊ុនថន ៖ អូសមងអី?

ម្ដាយ ដារ៉េត ៖ ចា៎! អាអូសមងយើងអីចេះណា អូសមងអីចេះឯង មងធំៗគេឲ្យទៅអូស មងមួយអូសពីរនាក់ៗ បានកំពឹសមកគេយកមកដាក់រោងជីវភាពកន្លែងបាយនេះឲ្យគេ ។

ប៊ុនថន ៖ តែហូបអីបាននេះដែរអ៊ី?

ម្ដាយ ដារ៉េត ៖ អត់ទេ ដែលពេលដែលទៅអីចេះ ទៅគេឲ្យមួយកំប៉ុងក្នាបួននាក់ ទៅដល់ទៅលាយត្រកួនលាយអីបបរដាក់កំពឹសដាក់អីលាយបានឆ្អែតនេះឯងលោកគ្រូ ហើយប្រពន្ធនៅផ្ទះក៏មានអីទុកឲ្យកូនញាំ បើអត់បានចែកបបរមួយ សុទ្ធតែទឹកទទេ មួយវែកៗមកសិរិតបានបាយគ្រាប់អង្ករចំនួនប្រហែលមួយស្លាបព្រា ឬក៏កន្លះស្លាបព្រា អត់មានច្រើនទេ ខ្ញុំទៅណោះក៏បានឆ្អែតនៅណោះនឹកមកកូន បានកក្ករកន្លះកំប៉ុងអីចេះទៅក៏បបរលាយៗត្រកួនល្ងាចឡើង ពេលព្រឹកក៏បបរកន្លះកំប៉ុងទៅ ពេលល្ងាចឡើងក៏បបរបានកន្លះទៀតទៅលាយត្រកួនលាយអីទៅ ដើរបោចត្រកួនលាយ លាយកំពឹសបាន

ផ្អែតប៉ុណ្ណេះឯងលោកគ្រូ មកដល់កូន ក៏កូនអស់ ទៅសុំកំពឹសគេមួយកំប៉ុង ក៏លីងឲ្យកូនហូប ។

ប៊ុនថន : បងគេអាយុប៉ុន្មានមីងកូនអ៊ឹ?

ម្ដាយ ដារ៉េត : បងគេមានអាប្រុសមួយនោះអាយុ២១ ។

ប៊ុនថន : បងគេអាយុ២១

ម្ដាយ ដារ៉េត : អាហ្នឹងកូនប្ដីមុនលោកគ្រូ អ្ហូ! កូនប្រពន្ធមុន ចុះគេហៅទៅធ្វើអី គេ ។

ជិតខាង : និរសារតាមង តាវ៉ាល់ ។

ម្ដាយ ដារ៉េត : និរសារតាមង តាវ៉ាល់ គេឲ្យធ្វើដកពីចល័តមកណាលោកគ្រូ ។

ប៊ុនថន : គាត់ធ្វើចល័ត?

ម្ដាយ ដារ៉េត : គាត់ធ្វើចល័ត ។

ប៊ុនថន : គាត់ឈ្មោះអី?

ម្ដាយ ដារ៉េត : ឈ្មោះ ធន់ ធឿន ។

ប៊ុនថន : ធន់ ធឿន?

ម្ដាយ ដារ៉េត : ធន់ ធឿន ។

ប៊ុនថន : បាទ! ហ្នឹងគាត់និរសារផ្ទាល់ តាមង តាវ៉ាល់ ម៉ង?

ម្ដាយ ដារ៉េត : ចាំ! ដល់ធ្វើបានប៉ុន្មានថ្ងៃនេះ គេវាយតាមង តាវ៉ាល់ ជម្លៀសទៅណាអស់ យកទាំងកូនខ្ញុំទៅផង ស្ងាត់ជ្រាប ។

ប៊ុនថន : មិនដឹងយកទៅណា?

ម្ដាយ ដារ៉េត : មិនដឹងយកទៅខាងណាទេរហូតដល់ប៉ុណ្ណេះធំ ។

ប៊ុនថន : ខាងណាអ្នកយកទៅអ៊ឹ?

ម្ដាយ ដារ៉េត : មិនដឹងខាងណាគេយកទៅ ខ្ញុំនៅស្រុកណោះ ឮថាគេយកទៅហើយដាក់ឡានទៅហើយ ឮដំណឹងអីចឹងលោកគ្រូ អត់បានឃើញផ្ទាល់ភ្នែកទេ គេឲ្យទៅជបលៀងឯណា ខ្ញុំមិនដឹងសួរស៊ើបគេទៅ ឮគេប្រាប់ថាអីចេះឯង គេឲ្យទៅជប់លៀងជាមួយតាមង តាវ៉ាល់ ហើយ មិនដឹងគេយកទៅខាងណាទេថាអីចេះ បាត់ពីហ្នឹងទៅលោកគ្រូ ។

ប៊ុនថន : កាលហ្នឹងគ្រួសារប្រពន្ធមុនរបស់អ៊ឹប្រុសប៉ុន្មាននាក់អ៊ឹកាលហ្នឹង?

ម្ដាយ ដារ៉េត : កូនគាត់ប្រាំ ។

ប៊ុនថន : ប្រាំនាក់ អីចឹងបាត់តែម្នាក់ឈ្មោះ ធឿន ទេ ។

ម្ដាយ ដារ៉េត ៖ បាត់ម្នាក់ ។

ប៊ុនថន ៖ ក្រៅពីហ្នឹងនៅរស់ទេអ៊ឹ?

ម្ដាយ ដារ៉េត ៖ នៅរស់ ស្លាប់មីស្រីមួយកាលឆ្នាំប៉ែតប៉ុន្មាន ៨៨ កាលឆ្នាំ៨៨ស្លាប់មួយ កើតកូនកាលណោះមិនទាន់មានពេទ្យ ។

ប៊ុនថន ៖ អ៊ីចឹងនៅសល់បីនាក់?

ម្ដាយ ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ ហើយអ៊ឹបួននាក់?

ម្ដាយ ដារ៉េត ៖ ចាំ! ខ្ញុំនៅបួននាក់ អូ! ប្រាំនាក់ ។

ប៊ុនថន ៖ ប្រាំនាក់ ។

ម្ដាយ ដារ៉េត ៖ ប្រាំនាក់ហ្នឹងក្រោយនេះ កាលមុនតែបីទេ ។ ខ្ញុំវេទនាពេក តានោះគាត់ឃើញ គាត់ស្រណោះគាត់យកខ្ញុំជួយចិញ្ចឹមកូន ចិញ្ចឹមអីទៅ បានធំបានអី សព្វថ្ងៃបានកូនពីរ ហើយមីតូចអម្បាញ់មិញមួយ អាប្រុសមួយនៅរៀន ។

ប៊ុនថន ៖ អ៊ឹនៅអូសមងរហូតអ៊ឹគេឲ្យអូស?

ម្ដាយ ដារ៉េត ៖ ចាំ! តាំងពីនេះមកអូសមងរហូតទាល់តែវៀតណាមចូល ។

ប៊ុនថន ៖ ចុះវៀតណាមចូលមក អ៊ឹធ្វើអីទៀត ដូចជម្លៀសទៅណាទៀតអ៊ឹ ក៏មកត្រឡប់មកភូមិវិញ?

ម្ដាយ ដារ៉េត ៖ មកភូមិវិញ ដឹកអីវ៉ាន់មកនៅភូមិ ពួកនោះគេទៅអស់ហើយ ។

ប៊ុនថន ៖ ដឹកពីភូមិ?

ម្ដាយ ដារ៉េត ៖ ដឹកពីភូមិប៉ោយសំរោងមកនៅភូមិខ្ញុំ ។

ប៊ុនថន ៖ ភូមិ ។

ម្ដាយ ដារ៉េត ៖ ចាំ!

ប៊ុនថន ៖ ភូមិនេះភូមិ?

ម្ដាយ ដារ៉េត ៖ ភូមិប៉ោយព្រីង ចាំ! ផុតពីនេះភូមិប៉ោយប៉ែន ។

ប៊ុនថន ៖ អ៊ឹដូចនេះ អ៊ឹស្គាល់ និយាយថា ប៉ោ លី ដូចថាពីបងប្អូនពីអីគាត់ទេ?

ម្ដាយ ដារ៉េត ៖ អត់មានស្គាល់ទេ ស្គាល់តែវាមួយហ្នឹងឯង ។

ប៊ុនថន ៖ ស្គាល់តែមួយទេ?

ម្ដាយ ដារ៉េត ៖ ចាំ!

ប៊ុនថន ៈ ចិន ឬមួយយ៉ាងម៉េចវិញ?

ម្ដាយ ដារ៉េត ៈ ទេចិនកូនកាត់នេះឯង កូនកាត់ចិន ប៉ុន្តែស្លាប់អស់ហើយ លោកគ្រូអើយពុថា ដែលចេញទៅពីភូមិ មិនដឹងថាចេញទេ ប៉ុន្តែយប់ឡើងគេថា ពួកខ្មែរក្រហមស្ទាក់បាញ់នៅឆ្នងណា ។

ប៊ុនថន ៈ កាលហ្នឹងរត់ទៅឆ្នាំ៧៩ដែរ ពេលវៀតណាមចូល?

ម្ដាយ ដារ៉េត ៈ ចា៎! ឆ្នាំ៧៩ ។

ប៊ុនថន ៈ ចុះអ៊ំដូចបើសិនជាចិត្តអ៊ំអីចឹងណាដូចថានៅខឹងជាមួយអ្នកដែលយកអីទៅទេ ចិត្តអ៊ំផ្ទាល់ណា?

ម្ដាយ ដារ៉េត ៈ សព្វថ្ងៃលោកគ្រូ?

ប៊ុនថន ៈ បាទ?

ម្ដាយ ដារ៉េត ៈ បើពីដើមខ្ញុំខឹងដែរ ប៉ុន្តែសព្វថ្ងៃនេះខ្ញុំសុំសីលហើយ ខ្ញុំថាកុំឲ្យមានចងកម្មចងពៀរគ្នាតទៅទៀត ក្រែងវាជាប់កូនជាប់ចៅទៅមុខទៅទៀត ខ្ញុំសុំស្មាលាហើយ ខ្ញុំចូលសមាទានសីលហើយ ។

ប៊ុនថន ៈ ហើយអ៊ំគិតថា ។

ម្ដាយ ដារ៉េត ៈ កាលពីមុនខ្ញុំខឹងមែនទែន ដូចថាឈាមសងឈាម ជីវិតសងជីវិត ប៉ុន្តែសព្វថ្ងៃខ្ញុំកាត់ចិត្តហើយ ព្រោះខ្ញុំចូលសមាទានសីល សមាទានកិច្ច ។

ប៊ុនថន ៈ ចុះអ៊ំមានអីចង់បន្ថែមទេ ខ្ញុំអត់បានសួរកន្លែងខ្វះណាអ៊ំ ព្រោះថាអ៊ំអត់ទាន់បានរៀបរាប់ណា ។

ម្ដាយ ដារ៉េត ៈ រៀបរាប់ពីគ្រួសារខ្ញុំមុន?

ប៊ុនថន ៈ បាទៗ! អាកន្លែងណាដែលអ៊ំចងចាំ ហើយមានអនុស្សាវរីយ៍អីអ៊ំចង់រៀបរាប់ហ្នឹងដែលខ្ញុំអត់បានសួរណា?

ម្ដាយ ដារ៉េត ៈ ខ្ញុំចង់រៀបរាប់ដែលកូនខ្ញុំ អូ! ដែលយកប្ដីខ្ញុំទៅនោះ ខ្ញុំកូនខ្ចីពីរខែ អូ! បីខែ មិនមែនពីរខែទេ បីខែ ហើយកូនខ្ញុំអាប្រុសនេះវាហើមជើង ហើមជើងហើមដៃ ផុតគ្រោះពីហើមស្រាប់អស់ទៅ ដោយហេតុដៃជន្យកូនខ្ញុំមួយនេះអត់ស្លាប់ ហើមគ្នាដើរអត់រួច ស្រាប់តែស្អែកឡើង ហើមយូរហើយប្រហែលកន្លះខែ ស្រាប់តែស្អែកឡើងខ្ញុំក៏ស្គមលោកអើយអត់ដឹងថាខ្លួនឯងស្គមទៀត គេឲ្យទៅកិនស្រូវ មកឈប់ធ្វើជីវកម្មគេឲ្យកិនស្រូវ ទៅកិនស្រូវឃើញបងម្នាក់ បងភឿន ទៅនៅពោធិ៍សាត់ គាត់

មកជម្រៀសមកដែរណា ខ្ញុំថា បង បងឯងម៉េចក៏ស្គម បងបងភ្លៀន ឯង ម៉េចក៏ស្គម បងភ្លៀន គាត់ថា ចុះបង យ៉ាត ឯងម៉េចក៏ស្គមដែរ លោកគ្រូឯងមើល អត់មើលខ្លួនឯងផង បំណាច់ភ័យណា អត់មើលខ្លួនឯងសោះ អត់ដឹងថាស្គមយ៉ាងណាទេ ស្រាប់តែកិនស្រូវរួចមកផ្ទះៗ នឹកឃើញ ផ្លូតទឹកនឹកឃើញ បងភ្លៀន គាត់ថាម៉េចថាខ្លួនអញស្គម ដោះអាវបើក លោកគ្រូអើយគ្មានដើមគ្មានដូងអីទេ ដាប់នៅនឹងឆ្អឹង ឃើញតែចុងម៉ុចៗ អួយ! ទេវតាអើយខ្ញុំដល់ថ្នាក់នេះ លោកគ្រូអើយទើបភ្ញាក់ខ្លួន មិនដឹងប៉ុន្មានឆ្នាំទេខ្ញុំ មិនដែលមើលខ្លួនសោះ ព្រោះខ្លាចគេណាស់ ផ្លូតទឹកក៏មិនដែល ឯណាស្បឹតទាំងដៃស្បឹតទាំងជើង កប៉តកប៉ាត់ក៏មកណា មិនដែលធ្វើម៉េចបានឲ្យជ្រះ ក្អែលមិនទាន់ទេ ក្អែលណាស់... ហើយស្រាប់តែ ខ្ញុំមានអីហូបកាលណោះគេបបរប្រាំមួយកំប៉ុង គេធ្វើបីខ្ទះ អាខ្ទះត្នោតយើងអាធំនោះ អាខ្ទះកូរស្ករលោកគ្រូ មួយខ្ទះនោះគេដាក់បីកំប៉ុង តែគេសិតទឹកពីរដង សិតទឹក ពុះហើយគេសិតដាក់ពាង ពុះហើយគេសិតដាក់ពាង ដល់លើកទីបីនេះបានគេយកអាកាកនេះលាយក្រឡៃចូលគ្នា ហើយដួសចែកគ្នា ទៅអាខ្លះបានពីរគ្រាប់បីគ្រាប់ កូរទៅដួសចែកគ្នាម្នាក់ពីរវែកៗទៅ ហើយកូនខ្ញុំហើម អាបងនេះវាហើម ហើមនេះហើមគ្នាដើរមិនរួច មិនដឹងធ្វើម៉េចទេ ទៅស្នើស្ករគេក៏មិនហ៊ាន ទៅណាក៏មិនហ៊ាន ខ្លាចគេយកទៅវៃចោល ចោលកូនកំព្រាទៀត កំព្រាឪពុកនៅម្ដាយ ចេះតែខំប្រឹង ស្រាប់តែថ្ងៃណោះបានកូនងាំដែលបីខែនោះដេកឲ្យមីមួយនេះនៅមើលប្អូន នាងនេះមើលប្អូន ម៉ែទៅជីកក្ដួច កាលណោះថាដំឡូង អត់មានដំឡូងទេលោកគ្រូ រកអាក្ដួចដែលពុលៗណាក្ដួចហើយនិងក្ដឹស ក្ដួចក៏មិនមាន ក៏ឃើញក្ដឹសប៉ុណ្ណោះមួយ ម៉ាដុំមក ប៉ុន្តែមិនទាន់បានមកផ្ទះទេ ក៏នាំកូនដើរទៅទៀត អាកូននោះវាថា កុំអីក៏ខ្ញុំមិនបានទៅ ថាម៉ែអើយម៉ែបើអាអូនអីអត់ហូបទេ ខ្ញុំល្ហមដើររួចហើយ ខ្ញុំជូនម៉ែឯងទៅ ទៅរកដំឡូងឲ្យអាអូនញាំ កាលណោះនិយាយញាំ អត់និយាយហូប ម៉ែឲ្យអាអូនហូបក្រែងអាអូនរស់កូនក៏នាំខ្ញុំទៅ មកដល់ក្បែរគុម្ពឫស្សីត្រង់នោះ នៅក្បៀនៗនេះរកដំឡូងរកក្ដឹសក៏មិនបាន ក្ដឹសនោះពុលលោកគ្រូ ស្រាប់តែដល់បានក្ដឹសមួយដុំទៅក៏នាំកូនដើរទៅទៀតដើរទៅដល់ចន្ទុះ ដល់គេហៅចន្ទុះៗនោះ គេធ្វើចម្ការដំឡូង គេធ្វើចម្ការដំឡូងគាស់អស់ហើយដូចអន្ទងប៉ុនៗណោះៗក៏នាំកូនជីកអាអន្ទង់ចាស់គេណា ក្រែងលោឃើញបន្តិច ឃើញក៏ស្អុយប្រវែងប៉ុណ្ណោះមួយថ្នាំង អាដំឡូងមីណា គេអស់ហើយណា

ក៏កាប់មើល ដាបានប្រវែង១នេះក៏យកមកផ្សំគ្នាមកបានដាបន្តិចក៏ផ្សំគ្នាមក ដល់ចដន្យអីថ្ងៃ ប្រហែលជាម៉ោងមួយលោកគ្រូដាក់ត្រង់នេះកាប់គិប១១ ក៏ទន្រ្តាំមួយគិបទៀតទៅលោកគ្រូអើយបានហ៊ីងប៉ុណ្ណោះ គេក៏កំពុងធ្វើចម្ការ គេក៏កំពុងដឹកធ្វើគល់ណាដល់កូនខ្ញុំបានហ៊ីងមួយដូចទេវតាប្រោះ លោកគ្រូអើយតាំងពីម៉ោងមួយរហូតដល់ម៉ោងបី ម៉ែអើយដុតហ៊ីងនេះ កូនអើយកំដុតអី ចាំម៉ែរកបន្លែមកស្ងបាន កូនហូបទាំងអស់គ្នា បានម្នាក់មួយម៉ាត់កូន ចែកបងហូបផង ហើយឲ្យប្អូនយើងហូបផង បានមានជាតិទាំងអស់គ្នា កូនខ្ញុំក៏ចេះកាន់ហ៊ីងសម្ងីង វាឃ្លានណាស់ គ្នាមិនដែលបានអីហូប ម៉ែអើយដល់ដីងចំនួន១០ដង បានខ្ញុំដាច់ចិត្តថា ដុតក៏ដុតទៅកូន វាដុត ក៏យកហ៊ីងហ្នឹងទៅដុត ដល់យកហ៊ីងទៅដុត វាហូប ដល់វាហូប ម៉ែអើយហូបក្ងាមួយទៅម៉ែ ទេកូនអើយម៉ែមិនហូបទេ ម៉ែខំរកដំឡូង កូនឯងហូបទៅ ឲ្យកូនឯងដា ។

ប៊ុនថន ៖ កូនហើមជើងហ្នឹងអ្វី?

ម្តាយ ដារ៉េត ៖ ចា៎! ហើមជើង ប៉ុន្តែក្បាលវាអត់ហើម នេះដែលងាប់វាហើមក្តផង វាហើមជើងផង វានេះអត់មានហើមក្តទេ ហើមតែក្ងាជិតគ្នាណាលោកគ្រូ ។

ប៊ុនថន ៖ ដើរអត់រួចទេ?

ម្តាយ ដារ៉េត ៖ ដើរអត់រួចទេ ស្រាប់តែស្អែកឡើងវាថា ម៉ែអើយខ្ញុំវាអត់ ល្មមដើររួចហើយខ្ញុំជូនម៉ែឯងទៅ ទៅដឹកដំឡូងឲ្យអាអូនហូប ក្រែងអាអូនរស់ ។ ខ្ញុំក៏ចោលកូនងាំបីខែនៅអង្រឹងក៏ឲ្យមីនេះមើល បានហ៊ីងនោះឯង ដល់ហូប វាហូប១អត់ហ៊ានអស់ទេ ម៉ែអើយហូប ម៉ែហូបមានកម្លាំងណាម៉ែ ។

ប៊ុនថន ៖ កូនដែលឈឺហើមជើងហ្នឹង?

ម្តាយ ដារ៉េត ៖ ចា៎! មើលនេះកូនវា ហូបទៅកូន មិនបាច់ទុកឲ្យម៉ែទេ ទេម៉ែឯងហូបមួយម៉ាត់ទៅលោកគ្រូអើយវាគេស១ក៏សល់ឆ្អឹងជំនីមួយចំហៀង អត់ហ៊ានស៊ីទេ យកមកឲ្យខ្ញុំទៀត ម៉ែអើយ ម៉ែឯងហូបតែប៉ុណ្ណេះទៅ ម៉ែឯងបើសាច់ខ្ញុំហូបអស់ហើយ បើម៉ែឯងមិនហូប ហូបឆ្អឹងជំនីនេះទៅ យី! កូនចេះ ដល់ខ្ញុំទៅយកមកហូប លោកគ្រូអើយប៉ុនចាក់ថ្នាំម្ជុលក៏មិនបានដូច ប៉ុនហូបបាយបានឆ្អែតពេញពោះក៏មិនបាន ដូចទេវតាប្រោះអីចេះឯង ថាវាមានកម្លាំង វាមានស្អីទៅណា ហើយកូនខ្ញុំទៅជានឹងអាហ៊ីងមួយនេះឯង បានហ៊ីងមួយនោះក៏ ស្អែកឡើងក៏ស្រកធេងទាំងអស់ ខ្ញុំក៏មានកម្លាំងដែរឆ្អឹងជំនីហ៊ីងមួយចំហៀងនេះឯង មានកម្លាំងដើរមកដឹកដំឡូងបានប៉ុណ្ណោះ

មកក៏បបរឲ្យកូន កូនងាំនោះឯង គ្រឡេកឃើញតែខ្ញុំកណ្ដៀតតែចប កណ្ដៀតតែ កញ្ជើ បីខែណាលោកគ្រូ ចេះស្រែកហៅម៉ែៗ មើលស្រមោចរោមឡើងក្រហម នៅអង្រឹង ឲ្យមីបងនេះមើល វាអត់ដែល វាឃ្លានដែរ វាទៅឈរមើលនៅក្រោម ផ្ទះប្រធាន ហើយគេទម្លាក់ឆ្អឹង ទម្លាក់ឆ្អឹងទៅក៏នាំគ្នារើសស៊ី ។

ប៊ុនថន : ប្រធានអីគេវិញអ៊ី ប្រធាន ប្រធានភូមិ?

ម្ដាយ ដារ៉េត : ប្រធានភូមិ ។

ដារ៉េត : ប្រធានភូមិរោងបាយគេនិរតី កងប្រធានគេមកហូបបាយ ហូបសាច់ជ្រូក ហូបសាច់ ស្ងោរ យើងទៅឈរឱបសរសេរ គេបោះមកយើងប្អូនប្រាំនាក់ទៅ ដណ្ដើមគ្នាឆ្អឹង ។

ម្ដាយ ដារ៉េត : ចាំ! សុទ្ធតែកូនក្មេងប៉ុណ្ណេះឈរឱបសរសេរចាំគេទម្លាក់ ដល់អាវ៉ា អាណោច អាធ័មកូន ខ្ញុំអាណោចអាធ័ម ខ្ញុំយំអើយយំលោកគ្រូអើយ ខ្ញុំងាប់នឹងយំហ្នឹងកាល ណោះ ថាមិនរស់ទេខ្ញុំ ណាឃើញកូន មីមួយទៅឈរឱបចាំគេទម្លាក់ឆ្អឹង មួយកូនងាំ បីខែចេះស្រែកហៅម៉ែៗ លោកៗនៅក្នុងអង្រឹង ប៉ុន្តែកូនហ្នឹងស្លាប់ហើយ មិនមាន ទឹកអីសោះ លោកគ្រូមកដល់អើយដងទឹកដ្ដិលបានបញ្រ្ចកកូនម្ដងក្បង់ដាក់ៗមាត់កូន ឲ្យដឹក កូនក៏ដឹកទៅ ទៅមានជាតិអីលោកគ្រូ ទឹកទទេនោះ បានប្រហែលជាចំនួនមួយ ខែដាង ដាច់ដោះ ដាច់នេះហើយ បានបញ្រ្ចកៗតែទឹក កូននោះស្លាប់ទៅ ។

ប៊ុនថន : កូនណា កូនដែលហើមជើងហ្នឹង?

ម្ដាយ ដារ៉េត : អត់ទេ អាហើមជើងវារស់ ក្រោយទៀតអាប្អូនៗ ប្អូនពីរនាក់ស្លាប់ ប្អូនពីរនាក់ បន្ទាប់វា ប្រុសទាំងពីរ មួយនោះកើតព្រូនៗវាមានថ្នាំដាក់ព្រូនក៏ព្រូនចេញពីមាត់ ពីច្រមុះ បើយោលនៅអង្រឹង អូ! ព្រូនងាប់ទៅ អានោះអាបង អានោះអាក្រោយ ទៀតអាបីខែចេះហៅម៉ែៗ មកលើកឲ្យកូនផ្ទូតទឹក ចុះបើល្ងាចហើយលោកគ្រូអើយ វាចេះក្ដៅខ្លួនយ៉ាងណាទេ ក៏មិនដឹងធ្វើម៉េច នៅមើលកូនទៅខ្វាចអាបីនាក់នេះស្លាប់ ម្ល៉ោះហើយដាច់ចិត្តណាលោកគ្រូ ខ្ញុំបាបក៏មិនដឹង ខ្ញុំថាកូនអើយកូនមិនដឹងធ្វើម៉េចទេ បើនៅក៏ម៉ែមិនដឹងមានអីចិញ្ចឹមកូនឯងបានរស់ ម៉ែទៅក៏ម៉ែទៅរកឲ្យកូនឯងហូប បាន មិនបានក៏ម៉ែចេះតែទៅ កូនអើយកូនឯងដេកនៅអង្រឹងចាំម៉ែទៅ សង្ឃឹមមីបងនេះ យោលចុះ មីបងនេះនៅតូចដែរណោះ ឈរឱបតែសសរចាំគេទម្លាក់ឆ្អឹង តែទម្លាក់ ឆ្អឹងក៏រត់ដណ្ដើមគ្នាស្រូ រត់ទៅមិនដឹងជាបានមិនបានទេ សំប៉ែតនៅអាកូនណោះ អើយ វេទនាណាស់កូនងាំ ។

ប៊ុនថន ៖ ចុះបងស្រីមិញថាស្គាល់ ប៉ោលី ហ្នឹង ។

ដារ៉េត ៖ ប៉ោឡេង?

ប៊ុនថន ៖ បាទ! ប៉ោ ឡេង ហ្នឹង ប៉ោឡេង ហ្នឹងបងថាមកគ្រួសារមានម្ដាយមានអីមកដែរអី?

ដារ៉េត ៖ មកមួយក្រុមគ្រួសារ គ្រួសារមកនៅជាមួយគ្នាទាំងអស់ ។

ប៊ុនថន ៖ នៅណាកាលហ្នឹង?

ដារ៉េត ៖ កាលហ្នឹងដូចនៅផ្ទះតាហារនោះឯង

ប៊ុនថន ៖ នៅភូមិអីវិញ?

ដារ៉េត ៖ ប៉ោយសំរោងជាមួយគ្នានោះឯង?

ប៊ុនថន ៖ ប៉ោយសំរោង?

ម្ដាយ ដារ៉េត ៖ ចា៎!

ប៊ុនថន ៖ ច្រើនទេអី អូ! បងអ្នកភ្នំមកហ្នឹង ក្រៅពីគ្រួសារ ប៉ោ លី ហ្នឹង មានអ្នកផ្សេងទៀតទេ?

ម្ដាយ ដារ៉េត ៖ មានអ្នកផ្សេង ។

ដារ៉េត ៖ ច្រើនណាស់លោកគ្រូ ម៉ាប៉ោយសំរោងរាប់ពាន់គ្រួសារ ។

ប៊ុនថន ៖ សុទ្ធតែអ្នកថ្មី?

ដារ៉េត ៖ ចា៎! សុទ្ធតែរាប់ពាន់គ្រួសារ ប៉ុនមិនដឹងមកពីភ្នំពេញ មិនដឹងមកពីខាងណាទេច្របូកគ្នាទាំងអស់ច្របល់គ្នាទាំងអស់ ។

ប៊ុនថន ៖ បាទ?

ដារ៉េត ៖ ខ្មោចងាប់មួយថ្ងៃពីររយនាក់ ។

ប៊ុនថន ៖ អូ! ងាប់ដោយសារអីវិញអ្នកមីង?

ម្ដាយ ដារ៉េត ៖ សែង ។ អ្នកសែងនោះងាប់ទៀត ។ អាអ្នកសែងក៏ងាប់ អាងាប់អាអ្នកដែលអត់បាយហ្នឹង ។ មួយថ្ងៃមួយថ្ងៃទៅសែងរួចទៅ អាអ្នកសែងនោះវាងាប់ដែរ ។

ប៊ុនថន ៖ បាទ!

ម្ដាយ ដារ៉េត ៖ ងាប់ដល់រកនរណាសែងណាមិនបាន ។

ប៊ុនថន ៖ ចឹងបងឃើញដែរសែងខ្មោចស្លាប់ហ្នឹង?

ដារ៉េត ៖ ចា៎! ខ្ញុំឃើញ ។

ប៊ុនថន ៖ ហឺ?

ដារ៉េត ៖ ខ្ញុំនៅតូច ខ្ញុំលេងដីខ្សាច់ ជញ្ជូនដីទៅឃើញ សែងកណ្ដាប់ ។

ប៊ុនថន ៖ អត់ខ្លាចទេចឹង?

ដារ៉េត ៖ អត់ដឹងខ្លាចអីផង ខ្លាចគេវាយចោលៗនៅមុខហ្នឹង ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ ខ្ញុំក៏ហូបដីហូបអីក៏ដឹកទឹកបំពេញក្រពះទៅ ។

ប៊ុនថន ៖ ចោះ ប៉ោ លី ហ្នឹង?

ដារ៉េត ៖ ប៉ោ ឡេង ។

ប៊ុនថន ៖ គ្រួសារមកប៉ុន្មាននាក់បងទាំងឪពុកម្ដាយ?

ដារ៉េត ៖ មិនដឹងជាប៉ុន្មាននាក់ ប៉ុនដឹងថានៅមិននៅតែគាត់ទេ ។ គាត់នៅជាគ្រួសារ មួយផ្ទះនោះប្រហែលបីបួនគ្រួសារ ម៉ាផ្ទះនោះគេរើហើយ ។ ផ្ទះនោះ ផ្ទះទាម ។

ប៊ុនថន ៖ បាទ?

ដារ៉េត ៖ និយាយចឹងកុមារគេឲ្យទៅដេក ថាគេសុំម៉ែឲ្យទៅដេក ។

ប៊ុនថន ៖ បាទ?

ដារ៉េត ៖ ដេកគេជាន់ខ្ញុំឡើង ។

ប៊ុនថន ៖ នៅហ្នុងមានគេឲ្យកុមារៗឲ្យទៅដេកនៅហ្នុង?

ដារ៉េត ៖ ចា៎! ឲ្យទៅដេកអាកន្លែងសាលាកុមារ ។ កាលនោះបើប្រធានខ្ញុំ នរណាខ្ញុំអត់ស្គាល់ទេ ស្គាល់មុខប្រធានខ្ញុំម៉េចៗខ្ញុំអត់ស្គាល់ ។

ប៊ុនថន ៖ ប៉ោ លី ហ្នឹងគេជ្រើសរើសឲ្យចូលធ្វើប្អូកម៉េចដែរបង?

ដារ៉េត ៖ ខ្ញុំបានអត់ដឹងថាគេជ្រើសរើសឲ្យធ្វើម៉េចទេ ។ ដឹងតែគេធ្វើឈ្លបៗ ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ ឃើញគេក៏ខ្លាចឡើងវិញ ។

ប៊ុនថន ៖ ហីកាច់ទេ ប៉ោ លី អីហ្នឹងដូចថាអ្នកថ្មី?

ដារ៉េត ៖ អ្ហ៎! មិនដែលបានជួនមុខថាកាចផង ព្រោះឃើញតែគាត់ចេះតែគាត់ ។ ឧទាហរណ៍ថាខ្ញុំឃើញកាលម្ដងនោះ ឃើញកន្លែងផ្ទះអ៊ំគិត ទៅដល់ហ្នុងនិរតីវាប្រលែងជាមួយនាយចិត្ត ។ នាយចិត្តនោះស្អាត ណា៎! គេហៅអា ប៉ោ ឡេង ខ្ញុំចំណាំបានតែប៉ុណ្ណោះឯង ។

ប៊ុនថន ៖ នាយចិត្តម៉េចមីង?

ដារ៉េត ៖ នាយចិត្តហ្នឹងគាត់ស្អាត ស្អាត់ស ។ នាងនិរតីឲ្យតែនរណាស្អាតវាលេង អាឡឹប វា ស្រឡាញ់ ។

ប៊ុនថន ៖ អូ! នាយចិត្តហ្នឹងពីណា?

ដារ៉េត ៖ នាយចិត្តហ្នឹងអ្នកតាប៉ែន ។

ប៊ុនថន ៖ អ្នកតាប៉ែន?

ដារ៉េត ៖ ចា៎! នៅភូមិជាមួយខ្ញុំកាលប៉ោយសំរោង ខ្ញុំចាំបានកាលប៉ុណ្ណោះឯង ។

ម្ដាយ ដារ៉េត ៖ ចិត្ត អ្ហា៎!

ដារ៉េត ៖ ចិត្ត បងឈឿកនោះ ប្រលែងគ្នាជាមួយជាមួយមីកា យ៉ន និរតី ដែលគាត់ស្អាត់ នោះ ។ គាត់សាច់ស គាត់មកពីភ្នំរនោះ និរតីប្រលែងឡិប ។

ប៊ុនថន ៖ អ៊ីចឹង?

ដារ៉េត ៖ ប៉ុ ប៉ោ ឡេង គេនោះនិរសារ ឈ្លប ទៅ ។ និរតីប្រើទៅណាក៏ទៅ ប៉ុ ប៉ោ ឡេង នោះសស្អាតដែរនោះ និរតីវាស្រលាញ់ដែរលើកឲ្យធ្វើឈ្លប ។ ឲ្យតែនរណាស្អាត ដូចលោកគ្រូឯងនិរតីវាឡិបជាប់ ។

ប៊ុនថន ៖ បាទ! ចឹងស្រីៗហ្នឹងសុទ្ធតែប្រធានៗហើយ?

ដារ៉េត ៖ និរតី ចា៎! ប្រធានៗហ្នឹង ។

ម្ដាយ ដារ៉េត ៖ ឲ្យតែមកដប់នាក់ប្រធានទាំងដប់នាក់ ។

ដារ៉េត ៖ ប្រធានទាំងប្រធានភូមិទៀត ហ្នឹងនិរតី ។ ប្រធានភូមិក៏ខ្លាចនិរតី ។

ប៊ុនថន ៖ ក្មេងៗដែរ?

ដារ៉េត ៖ ក្រមុំៗ ។

ម្ដាយ ដារ៉េត ៖ សុទ្ធតែក្រមុំ ។

ដារ៉េត ៖ សុទ្ធតែក្រមុំ ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ អាខ្លះក៏១៦ អាខ្លះក៏២២ ។

ដារ៉េត ៖ កាត់សក់ស្ញើក ក៏សសណ្ដុកៗ ។

ប៊ុនថន ៖ បាទ! ចឹង ប៉ោ ឡេង ហ្នឹងដោយសាររូបរាងសមស្អាត សមរម្យអ៊ីចឹងបានខាងនិរតី ឲ្យធ្វើឈ្លប?

ដារ៉េត ៖ ចា៎! នោះឯង ។

ប៊ុនថន ៖ ចោះដូចអ្វី?

ដារ៉េត ៖ ខ្ញុំចាំមិនបានច្បាស់ទេ ចាំបានតែ ខ្ញុំនៅតូចដែរហ្នឹង ។ ខ្ញុំរត់លេងទៅខ្ញុំឃើញគេហីក៏ ។

ប៊ុនថន ៖ ដូចថាប្រលែងគ្នាអីចឹងអត់មានខុសអីទេ?

ដារ៉េត ៖ អត់ខុសអីទេ បើយើងខុសទាំងអស់ ។

ប៊ុនថន ៖ បើសិនជាប្រជាជនអត់បានទេ?

ម្ដាយ ដារ៉េត ៖ បើសិនជាប្រជាជនវាយចោលបាត់ហើយ អត់ទុកទេ ។

ដារ៉េត ៖ ចាំ! ហីយើងដូចថាអ្នកស្រែ អ្នកចម្ការអីចេះ បានឲ្យវាមកលួនឹងយើង ប្រពន្ធប្ដីក៏កូនយើងអីមិនហ៊ានថាទេ ។ ឲ្យគេលួនឹងយើង១រស់បានយូរហើយ គេឲ្យអានេះអានោះហូបផងបានហូប ។

ប៊ុនថន ៖ ចោះមានដូចខាងឈ្លបប្រុស១អីមក ដូចថាមកអីឃើញកូនអ្នកភូមិស្អាតអីចឹងមកមានដេះមីង?

ដារ៉េត ៖ អត់មានទេ អាហ្នឹងអស់មានទេ ។ ណា៎! ម៉ែ កូននរណាស្អាត១អត់មានទេ ព្រោះនារី១ នៅតាមចល័តទាំងអស់ ។

ម្ដាយ ដារ៉េត ៖ ចល័តទាំងអស់អត់មាននៅផ្ទះ ។

ដារ៉េត ៖ អត់មាននៅផ្ទះទេ ស្វាត់ ។

ម្ដាយ ដារ៉េត ៖ បានត្រឹមអាយុដប់បីគេដកចល័តទាំងអស់ ។

ដារ៉េត ៖ ខ្ញុំឆ្ងល់អញ្ចេះលោកគ្រូ ខ្ញុំចង់សួរលោកតាដែលគាត់ដឹកនាំប្រទេសជាតិសម័យបីឆ្នាំហ្នឹងណា៎! គាត់រៀនដល់ថ្នាក់ណាបានគាត់ដឹកនាំប្រទេសជាតិឲ្យបែបនោះខ្ញុំឆ្ងល់មែនទែន ណា៎!

ប៊ុនថន ៖ បាទ!

ដារ៉េត ៖ នោះឯងខ្ញុំឆ្ងល់មែនទែន ។

ប៊ុនថន ៖ ហ្នឹងទៅបន្តិចទៀតគេកាត់ទោសគាត់ ។ ថ្ងៃ២៨ ខែហ្នឹងគេចាប់ផ្ដើមកាត់ទោសគាត់ ។

ដារ៉េត ៖ ថាគាត់រៀនដល់ថ្នាក់ណាបានជាគាត់ដឹកនាំប្រទេសជាតិ ហើយស្រូវសម័យបីឆ្នាំនោះខ្ញុំនេះលួចកាច់កន្ទួរគេប្រាំកួរក៏គេចាប់ មួយកួរក៏គេចាប់ ។ និយាយពីស្រូវកន្លែងណាក៏អត់មានថាស្រូវមិនកើតដែរ កើតគ្រប់ទិស ។ ហីការងារសម្រាកមួយថ្ងៃ ឈឺយ៉ាងណាតែយើងហ៊ានសម្រាកសតិអារម្មណ៍ យកយើងទៅវាយចោល ។ ថាធ្វើការងារប្រកបការងារអីគឺកើតទាំងអស់ តើលទ្ធផលនោះយកទៅណាខ្ញុំឆ្ងល់ដល់ហើយ ។

ប៊ុនថន ៖ បាទ!

ប្រុញ ៖ ពេលស្រូវកំពុងផ្លែកំពុងអី ដីអត់មានលើកទំនប់លើអី គេឲ្យយើងធ្វើអីគេ?

ដារ៉េត ៖ គេឲ្យយើងធ្វើស្រែ យើងដូចថាខ្ញុំកុមារជី ចិញ្ច្រាំជី ដូចម៉ែខ្ញុំចេះទៅដកទៅស្ទូង ។

ម្ដាយ ដារ៉េត ៖ ដាក់កូនទាង ។

ដារ៉េត ៖ អត់ឲ្យទំនេរប៉ុនក្រចកទេ ហើយស្រូវស្រែដីងតែកើត ។

ប្រុញ ៖ ឧទាហរណ៍ស្រូវចេញហើយវាត្រូវទំនេរ ហីពេលហ្នឹងយើងទៅធ្វើអីវិញទៅ?

ម្ដាយ ដារ៉េត ៖ ពេលទំនេរ!

ដារ៉េត ៖ អត់ដែលមានទំនេរទេ ធ្វើចម្ការ ។

ម្ដាយ ដារ៉េត ៖ ដែលមានទំនេរសោះ ។ ចម្ការដាំដំឡូង ។

ដារ៉េត ៖ កាប់ចម្ការ លើកទំនប់ ។

ម្ដាយ ដារ៉េត ៖ ត្រូវមុខព្រួញលើកទំនប់ ត្រូវមុខព្រួញគេឲ្យទៅ ។

ប៊ុនថន ៖ បាទ! អឹមញ្ញើញនិយាយទៀតទៅ?

ដារ៉េត ៖ ខ្ញុំតែទឹកមួយដ្ដិលយោងមិនរួចម្ដង១ ។

ម្ដាយ ដារ៉េត ៖ មុនព្រួញគេឲ្យទៅធ្វើចម្ការ ទៅធ្វើចម្ការ មិនមានទំនេរសោះ ហើយម៉ែ១នៅផ្ទះ មានដាក់កូនទាង បេះស្លឹកមក ចាំ! ហីមានម៉ែខ្លះនោះមើលចៅ ដូចខ្ញុំសសៃខ្ចីកូនខ្ចី ពីរខែបីខែយកទៅទុកឲ្យគាត់ គាត់មើល ។ ខ្ញុំក៏ទៅបាត់ទៅ ទៅស្ទូង ខ្លះត្រូវស្ទូង១ ត្រូវដក១ ខ្លះត្រូវដាំដំឡូងដាំ អាខ្លះត្រូវគាស់គាល់ក៏គាស់ អត់មានពេលទំនេរថ្ងៃណាទេ ។

ដារ៉េត ៖ ហីខ្ញុំឆ្ងល់ម្យ៉ាងទៀតថាអញ្ចេះ ពួកគាត់១ធ្វើសម័យបីឆ្នាំនៅណោះ គាត់ថាអង្គការ១ចុះមក ។ វាមិនដែលឃើញអង្គការ មានតែឈ្លបគ្នាឯងក៏តិចតួច១មកលបមួយយប់១រាប់មិន មិនដែលមានអង្គការណាចុះមកឲ្យឃើញមុខ ឃើញមាត់អត់មានទេ ។ ហីម្យ៉ាងទៀតថា អង្គការ១បញ្ជូរមក អ្នកដែលមកកាន់កាប់ធ្វើប្រធានភូមិយើងនេះ សុទ្ធតែអ្នកភ័យខ្លួនថាគេយកគាត់មកសម្លាប់ចោលទេ ។ គាត់ភ័យដែរ ណាំ! គេយកគាត់មកសម្លាប់ចោល ។ គេមកដល់ភូមិយើងនេះ គេលើកគាត់ឲ្យធ្វើជាធំ អត់បានសម្លាប់ទេ ។

ប៊ុនថន ៖ ចោះអ្នកមីងពេលឪពុកអ្នកមីងស្លាប់ដឹងទេ?

ដារ៉េត ៖ ដឹងខ្ញុំដឹង យំវាល់ព្រឹកជាមួយម៉ែខ្ញុំ ។

ប៊ុនថន ៖ អ្ហូ! ដឹងដែរ?

ដារ៉េត ៖ ដឹង ។

ម្ដាយ ដារ៉េត ៖ ប៉ុណ្ណោះហើយ ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ ប៉ុណ្ណេះហើយ ឈឱបសសរចាំគេទម្លាក់ឆ្អឹង ។

ប៊ុនថន ៖ ហើបងដូចថាចង់សួរអារម្មណ៍របស់បងពេលបច្ចុប្បន្ន ឧទាហរណ៍ថា ដឹងថាមានអ្នកយកស្គាល់អ្នកដែលយកឪពុកអីទៅសម្លាប់អីចឹង ដូចថាមានអារម្មណ៍នៅខឹង ឬមួយក៏យ៉ាងម៉េច?

ដារ៉េត ៖ ទេ! ខ្ញុំនៅតែខឹង តែខ្ញុំមិនបានសុំសីលអញ្ចេះ ខ្ញុំដឹងតែខឹង ។ ខ្ញុំខឹងអាណាដែលខ្ញុំអត់ឃ្លាន ខ្ញុំហូបតែដីផ្សំនឹងទឹក ហើយគុកស្អុរគេនោះ ខ្ញុំទៅកកេរគុកគេអញ្ចេះក៏គេចាប់ខ្ញុំបោះដូចឈូង ។ គុកស្អុរវាពពុះស្អុរមក វាហូរទៅនឹងគុក គុកមកវាខ្មៅខ្ញុំក៏កកេរអាដីឥដ្ឋហ្នឹងយកមកជញ្ជក់យកជាតិ ។ គេចាប់ខ្ញុំបោះវិលដូចជាស្អីហ្នឹងហើយ ។ សំណាងហើយដែលគេមិនបោះក្នុងខ្ទះគ្នោត គេបោះទៅក្រៅ ។ ហើយមិនមែនជាអ្នក បើរាប់ទៅវាខ្សែឯង សាច់ឯងនោះឯង ។

ប៊ុនថន ៖ អ្ហូ!

ដារ៉េត ៖ គាត់ធ្វើតែលើនោះហើយ ។

ម្ដាយ ដារ៉េត ៖ មានដឹងបងដឹងប្អូនទេឆ្នាំកាលនោះ ។

ដារ៉េត ៖ ហើឃ្លានខ្លាំងចឹងក៏ចាប់ក្រលាត ចាប់ដឹងចក់ឲ្យតែបានហូប វាគ្រាន់ជាងហូបដី ។

ប៊ុនថន ៖ បាទ?

ដារ៉េត ៖ ចាប់គីង្គក់ក៏បែកហូប ហែកស៊ី ។

ម្ដាយ ដារ៉េត ៖ ពុលគីង្គកម្ដងថាងាប់ក៏រស់ ។

ដារ៉េត ៖ លួចពងមាន់ពងទាគេបានឲ្យតែប្អូនៗ ខ្លួនឯងអត់ ។

ប៊ុនថន ៖ បាទ?

ដារ៉េត ៖ ហើយបើមានគេស្អីត្រង់ណាបេះលួចទាំងអស់កាលនោះ ។

ម្ដាយ ដារ៉េត ៖ បោះមានកៅអីឲ្យលោកគ្រូអង្គុយ!

ប៊ុនថន ៖ អត់អីទេអ៊ំ ចប់ហើយ ។ ចឹងអ៊ំមានចង់បន្ថែមទៀតទេអ៊ំ អ៊ំអត់ចង់ ។ ខ្ញុំអត់បានសួរ?

ម្ដាយ ដារ៉េត ៖ ខ្ញុំអត់មាន ។ ខ្ញុំដល់ចប់អាខ្ញុំមកផ្ទះនេះហើយ ។

ប៊ុនថន ៖ បាទ?

ម្ដាយ ដារ៉េត ៖ ចាំ! យួនចូលហើយចប់ ។

ប៊ុនថន ៖ អឺមកផ្ទះវិញ?

ម្ដាយ ដារ៉េត ៖ ចាំ! សន្តិភាពហើយក៏ចប់ ។

ប៊ុនថន ៖ បាទ ។

«ចប់»